ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩**

**សវនាការលើកទី៧៣**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី
លោក ឌុច ផារី
កញ្ញា ណាតាចា វីស៊ែល រីសឺ
*(Ms. Natacha Wexels-Riser)*
លោក ម៉ាតូ គ្រីស្ពារ *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង
លោក អានីស អះមេដ *(Mr.Anees AHMED)*
លោក ប៉ាក ច័ន្ទលីណូ

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ (Mr. François ROUX)

លោកស្រី ហេឡឺន អ៊ុយណាក់

(Ms. Heleyn UÑAC)

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គឹម ម៉េងឃី

កញ្ញា ទី ស្រ៊ីនណា

លោក ហុង គឹមសួន

លោក អាឡាំង វ៉ែនណឺ

(Mr. Alain Werner)

លោកស្រី គ្រីស្ទីន ម៉ាទីណូ

(Ms. Christine MARTINEAU)

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កែវ កូវរតនៈ

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អានីស អះមេដ | អង់គ្លេស |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោកស្រី គ្រីស្ទីន ម៉ាទីណូ | បារាំង |

# កិច្ចដំណើរការនីតិវិធី

[០៩:១២:៤៦]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការរបស់យើង ។ ហើយដំណើរសវនាការថ្ងៃនេះ គឺយើងបន្តកិច្ចដំណើរការសវនាការដែលបានធ្វើពីម្សិលមិញហើយមិនបានចប់ គឺការទទួលនិងការពិនិត្យនូវការដាក់ស្នើសុំដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះរបស់ភាគី ។ ហើយម្សិលមិញ យើងបានធ្វើការបានមួយចំនួនហើយ ប៉ុន្តែដោយសារពីម្សិលមិញនេះ ឃើញថាមានភាពមិនច្បាស់លាស់ មិនប្រាកដប្រជា ដោយចុងក្រោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានសុំដកខ្លួនដើម្បីទៅពិភាក្សានិងផ្តល់លទ្ធផល ។ ហើយតាមការយល់ដឹងរបស់ខ្ញុំ គួរតែត្រូវបានភាគីរៀបរយនូវឯកសារនោះឲ្យបានត្រឹមត្រូវ ហើយមានបញ្ជីឲ្យបានច្បាស់លាស់ ដោយចង្អុលបង្ហាញនូវអត្តសញ្ញាណនៃឯកសារដែលប៉ុនប៉ងនឹងដាក់ហ្នឹង ឲ្យបានច្បាស់លាស់ មិនគប្បីលើកឡើងសរុបហុកសិប ចិតសិបដូច្នេះទេ វាខុសអំពីរបៀបនៃការស្នើសុំដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ។ គួរតែត្រូវបានរៀបចំនូវបញ្ជីឈ្មោះ នូវអត្តសញ្ញាណនៃឯកសារ ដែលស្នើសុំដាក់ពិភាក្សាដេញដោលនៅចំពោះមុខអង្គជំនុំជម្រះនេះច្បាស់លាស់ទាំងលេខ ERN ទាំងលេខ D ឬក៏លេខ E ហើយនិងឈ្មោះនៃឯកសារនោះផង ។ ពីព្រោះឯកសារខ្លះឈ្មោះដូចគ្នា ខុសតែបរិច្ឆេទនៃការចេញឯកសារតែប៉ុណ្ណោះ ។ នេះនាំឲ្យមានការភាន់ច្រឡំនៅក្នុងការពិនិត្យ ហើយក៏មានការមិនច្បាស់លាស់ មិនប្រាកដប្រជា ។ ហើយដូចជាម្សិលមិញអ៊ីចឹង លើកហើយស្រាប់តែ ទើបតែសុំខ្លួនថយទៅពិនិត្យពិចារណាពិភាក្សាឡើងវិញ ដែលព័ត៌មាននេះអង្គជំនុំជម្រះបានផ្តល់ជូនដល់ភាគីច្រើនសប្តាហ៍រួចមកហើយ ។

ជាកិច្ចបន្តសូមអញ្ជើញខាងតំណាងសហព្រះរាជអាជ្ញា ដើម្បីបញ្ជាក់នូវឯកសារដែលបានស្នើសុំដាក់ពិភាក្សា ដើម្បីពិភាក្សាដេញដោលនៅចំពោះមុខអង្គជំនុំជម្រះកាលពីម្សិលមិញ ។

**លោក អានីស អះមេដ៖**

លោកប្រធាន លោក លោកស្រី ចៅក្រម ជាទីគោរព! ខ្ញុំសូមចាប់ផ្តើមធ្វើការបំភ្លឺនូវការយល់ឃើញនូវអ្វីដែលបានកើតឡើងកាលពីម្សិលមិញ ។ យើងខ្ញុំសូមការអនុញ្ញាតពីលោក លោកស្រីចៅក្រម ដោយសារតែនៅពេលនោះ គឺយើងហៀបនឹងដល់ម៉ោងហើយ ដែលមិនអាចឲ្យខ្ញុំឆ្លើយតបពិស្តារបាន

ទៅនឹងបញ្ហាចោទមូលដ្ឋានមួយចំនួនដែលសួរឡើងដោយចៅក្រមឡាវ៉ែន៍ ។ ប៉ុន្តែនៅពេលនោះយើងមានចម្លើយរបស់យើង យើងគ្រាន់តែសុំលើកឡើងនៅព្រឹកឡើង ដោយសារតែពេលវេលាមិនគ្រប់គ្រាន់ ។

[០៩:១៦:៣៦]

ចំណុចទីពីរ ឯកសារដែលយើងស្នើសុំពិភាក្សាជាមួយនឹងមេធាវីការពារក្តី គឺវាផ្អែកទៅតាមការសង្កេតរបស់មេធាវីការពារក្តី ហើយវាមិនមានការភាន់ច្រឡំ ឬក៏ការយល់ច្រឡំទៅលើឯកសារទាំងនោះចេញពីខាងភាគីអយ្យការនោះទេ ។ ដូច្នេះទាក់ទងទៅនឹងចំណុចនេះ គឺខ្ញុំសូមឆ្លើយតបទៅនឹងសំណួរពីរដែលបានសួរឡើងដោយលោកចៅក្រម ឡាវ៉ែន៍ ។

សំណួរពីរនោះគឺថា ថាតើយើងមានឯកសារបកប្រែជាភាសាបារាំងចំពោះឧបសម្ព័ន្ធដែលបានដាក់នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ដែរឬទេ? គឺ E-61 ដែលឯកសារនោះមានឈ្មោះ ការរៀបរាប់និងលេខយោងភស្តុតាង ហើយនិងព័ត៌មានពិស្តារផ្សេងទៀតដែលលោកប្រធានទើបតែលើកឡើង ដែលខ្ញុំទាមទារស្នើសុំដាក់ឯកសារនេះចំពោះមុខអង្គជំនុំជម្រះ ។

សំណួរទីពីររបស់លោកចៅក្រម ឡាវ៉ែន៍ ថាតើអយ្យការ សហព្រះរាជអាជ្ញាចង់និយាយយ៉ាងម៉េច ទាក់ទងទៅនឹងឯកសារចំណាររបស់ជនជាប់ចោទដែលយើងបានលើកឡើងនៅក្នុងការដាក់ឯកសារថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ដែលក្នុងនោះមានឧបសម្ព័ន្ធ “គ” និង “ឃ” ។

[០៩:១៨:០៩]

ខ្ញុំសូមលើកឡើងបញ្ហានេះ ហើយខ្ញុំស្នើសុំពីលោក លោកស្រីចៅក្រមផ្តល់រយៈពេលឲ្យខ្ញុំប្រាំទៅប្រាំពីរនាទី ដើម្បីផ្តល់អំពីប្រវត្តិនៃឯកសារនេះ ។ ឯកសារដែលពាក់ព័ន្ធទៅនឹងជំលោះប្រដាប់អាវុធមាននៅក្នុងសំណុំរឿងតាំងពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ។ នៅក្នុងមាត្រា២.២ ទាក់ទងទៅនឹងការដាក់ឯកសារភាគីរួមទាំងសហព្រះរាជអាជ្ញាផងដែរនោះ គឺទាមទារឲ្យដាក់ឯកសារជាពីរភាសាផ្លូវការរបស់តុលាការ ។ សហព្រះរាជអាជ្ញាបានបំពេញទៅតាមលក្ខខណ្ឌនេះ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ហើយយើងបានធ្វើការត្រួតពិនិត្យជាមួយនឹងផ្នែកគ្រប់គ្រងតុលាការរួចហើយ ។

ដូច្នេះ ដើម្បីអាចបញ្ជូនឯកសារទាំងអស់នោះជាភាសាទីបីនោះអាចធ្វើទៅបាន ប្រសិនបើភាគីមានបំណងស្នើសុំ ។ ដូច្នេះហើយខ្ញុំសូមស្នើសុំ ហើយនិងបំភ្លឺជាមួយនឹងក្រឡាបញ្ជីថា តើមានការស្នើសុំឲ្យបកប្រែជាភាសាបារាំងដែរឬទេ?

បញ្ហាមួយទៀត គឺថាតើមានឯកសារប៉ុន្មានដែលបានភ្ជាប់ទៅនឹងឯកសារចុះថ្ងៃទី២៩ ខែមេសា

ឆ្នាំ២០០៩ ។ ថាតើឯកសារភ្ជាប់ទាំងអស់នោះមានប៉ុន្មានជាភាសាខ្មែរ ភាសាបារាំង និងអង់គ្លេស? ដូច្នេះខ្ញុំសូមចំណាយពេលមួយចំនួនឆ្លើយតបទៅនឹងឯកសារនេះ ។ គឺមានឯកសារ៤៣០ ដែលវាលើកឡើងអំពីរបាយការណ៍ និងព័ត៌មានទាក់ទងទៅនឹងកម្ពុជានិងវៀតណាម ។ ឯកសារនីមួយៗបានលើកឡើងអំពីការប៉ះទង្គិច និងការការជំលោះនៅថ្ងៃខុសគ្នាៗ និងទីតាំងខុសៗគ្នា ។ ឯកសារនោះគឺវាប្រមូលបានមកពីប្រភពអន្តរជាតិនិងជាតិ រួមទាំងកំណត់ហេតុគណៈកម្មាធិការអចិន្ត្រៃយ៍រួមទាំងបក្សកុម្មុយនីស្ដកម្ពុជាផងដែរ ។ ហើយឯកសារនោះវាស៊ីគ្នាទៅនឹងចម្លើយដែលលើកឡើងដោយ ណាយ៉ាន់ ចាន់ដា និងជនជាប់ចោទនៅក្នុងរឿងក្ដីនេះផងដែរ ។

[០៩:២០:៤៥]

នៅពេលនេះ ខ្ញុំសូមបញ្ជាក់អំពីការបកប្រែទៅលើឯកសារទាំងអស់នោះ ។ ឯកសារទាំងអស់មាននៅក្នុងសំណុំរឿងហើយ យ៉ាងហោចណាស់មួយឆ្នាំប្រាំខែរួចមកហើយមកទល់ពេលបច្ចុប្បន្ន ។ ចំពោះឯកសារបួនរយជាងនេះ ពីររយដប់ពីរគឺទាក់ទងទៅនឹងឯកសារដំណោះស្រាយដែលចុះនៅក្នុងខែកក្កដា ឆ្នាំ២០០៧ ។ ឯកសារមួយនោះ គឺយើងមានឃើញយោងនៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដែលចុះនៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ហើយឯកសារពីរទៀតគឺបានយោងទៅលើឯកសារដែលយើងបានដាក់ ។ ហើយឯកសារចំនួន១៩១ បានបង្ហាញនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨ គឺឯកសារ D60 មានចំណងជើងថា “ឯកសារស្នើសុំរបស់សហព្រះរាជអាជ្ញា ដើម្បីបង្ហាញអំពីជម្លោះប្រដាប់អាវុធនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ” ។

ដូច្នេះ ខ្ញុំសូមជម្រាបអំពីការទាមទារនិងលក្ខខណ្ឌនៃការបកប្រែ ហើយខ្ញុំនឹងបញ្ចប់ទៅលើការសង្កេតរបស់ខ្ញុំទៅលើចំណុចនេះក្នុងរយៈពេលពីរនាទីទៀត ។

[០៩:២២:០៩]

មេធាវីការពារក្ដី ហើយនិងមេធាវីរបស់ ខៀវ សំផន គឺគាត់បានលើកឡើងដូចគ្នាដែរនៅក្នុងសំណុំរឿងទីពីរ គាត់បញ្ជាក់ថាគាត់មិនមានឯកសារទាំងអស់នោះនៅក្នុងជាភាសាបារាំង ហើយដោយសារបញ្ហាដែលគ្មានឯកសារបារាំង ការជំនុំជម្រះគឺគួរតែបញ្ឈប់ ។ ហើយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដោយមានសំអាងហេតុនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ បានលើកឡើងថា យោងទៅតាមករណីនេះ ជនត្រូវចោទគាត់មានសិទ្ធិទទួលបានឯកសារបកប្រែជាភាសាខ្មែរ ចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ហើយនិងធាតុផ្សំនៃភស្តុតាងដែលមានចែងនៅក្នុងដីកាបញ្ជូន

រឿងជំនុំជម្រះទាំងអស់នោះ ។

ជនត្រូវចោទក៏មានសិទ្ធិទទួលបានឯកសារបកប្រែជាភាសាខ្មែរទៅលើដីកាបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពររបស់សហពហព្រះរាជអាជ្ញា និងលេខជើងទំព័រផងដែរ ។

ហើយចំណុចក្រោយ សហចៅក្រមស៊ើបអង្កេតសង្កេតឃើញថា ការបកប្រែឯកសារសំណុំរឿងគឺមិនមែនជាធាតុផ្សំនៃការបង្ហាញភស្តុតាងនៅចំពោះមុខសាលាដំបូងនោះទេ ។ ដូច្នេះហើយ វាមិនទាមទារឲ្យមានការបកប្រែទាំងអស់ទៅជាភាសារបស់ជនត្រូវចោទនោះទេ ។ អង្គបុរេជំនុំជម្រះតម្កល់ទៅលើបញ្ហានេះផងដែរ បានលើកឡើងថាឯកសារដោះបន្ទុកគួរតែបកប្រែទៅជាភាសារបស់ជនជាប់ផងដែរ ហើយនិងបកប្រែជាភាសារបស់មេធាវីផងដែរដើម្បីជួយទៅដល់ជនជាប់ចោទ ។ ហើយយើងយល់ស្របទៅលើចំណុចទាំងអស់នេះ ។

ចំណុចចុងក្រោយ ចំណុចសំខាន់ផងដែរ សហចៅក្រមស៊ើបអង្កេតបានសម្រេច ហើយនិងតម្កល់យល់ស្របជាមួយនឹងអង្គបុរេជំនុំជម្រះ ។ ហើយចំពោះការសរសេរសាលក្រម មេធាវី-- អង្គជំនុំជម្រះត្រូវផ្អែកទៅលើឯកសារទាំងឡាយដែលមាននៅខាងការពារក្តីនិងខាងអយ្យការ ។ ហើយចំណុចទាំងអស់នេះ គឺវាអនុវត្តដូចគ្នាដែរចំពោះការិយាល័យសហព្រះរាជអាជ្ញា ។

[០៩:២៥:៣០]

យើងខ្ញុំសូមដាក់ជូនសំណើដោយគោរពថា យើងបានគោរពទៅតាមលក្ខខណ្ឌក្នុងការកំណត់ដោយអង្គជំនុំជម្រះ ហើយយើងបានដាក់ជាពីរភាសា ហើយយើងបានធ្វើការដាក់ឯកសារនោះនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៩ ។

មេធាវីការពារក្តីគាត់យល់ហើយ គឺគាត់យល់ភាសាបារាំងផងដែរ ហើយខាងមេធាវីការពារក្តីជាតិ ក៏យល់ភាសាខ្មែរ ហើយមេធាវីការពារក្តីអន្តរជាតិយល់ភាសាបារាំង ហើយជនជាប់ចោទ ក៏អាចយល់ភាសាខ្មែរនិងបារាំងផងដែរ ។ ដូច្នេះហើយយើងមិនអាចបកប្រែទៅលើឯកសាររាល់គ្រប់ទាំងអស់នោះទេ ។ ហើយយើងក៏មិនអាចបកប្រែគ្រប់ឯកសារទៅជាបីភាសាផងដែរ ។

បញ្ហាមួយទៀតដែលលោកចៅក្រម ឡាវែន៍ បានលើកឡើងគឺទាក់ទងទៅនឹងចម្លើយរបស់ជនជាប់ចោទ។ មេធាវីការពារក្តីបានលើកឡើងឆ្លើយតបទៅនឹងសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ នៅពេលនេះមិនមែនយើងជាការបើកសវនាការឡើងវិញនោះទេ ហើយមិនមែនការដេញដោលភស្តុតាងឡើងវិញនោះទេ ។ ហើយយើងខ្ញុំមិនស្នើសុំឲ្យបើកដេញដោលសាជាថ្មីនោះទេ ។ អ្វីដែលយើងខ្ញុំស្នើសុំ

នោះគឺយើងត្រូវគោរពទៅតាមសេចក្ដីបង្គាប់របស់អង្គជំនុំជម្រះ ។

[០៩:២៥:៥៣]

លោក លោកស្រីចៅក្រម នៅក្នុងប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ អង្គជំនុំជម្រះនៅថ្ងៃនេះ និងម្សិលមិញត្រូវពិចារណាបញ្ហានីតិវិធីដែលវាពាក់ព័ន្ធទៅនឹងការដាក់ឯកសារដោយអនុលោមទៅតាមវិធាន៨៧ ។ ហើយយើងបានអនុវត្តទៅតាមហ្នឹង ។ ហើយយើងបានផ្ដល់ការជូនដំណឹងនៅថ្ងៃទី៩ ខែសីហា រួចហើយ ។ ហើយឯកសារទាំងអស់នោះគឺមាននៅក្នុងសំណុំរឿងតាំងពីពេលដាក់ដីកាបញ្ជូនរឿងឲ្យទៅស៊ើបសួរនៅថ្ងៃទី១៩ ខែកក្កដា ។ ហើយមេធាវីការពារក្ដីគាត់បានយល់ទៅលើចំណុចទាំងអស់នេះ ។

ដូច្នេះ យើងមិនចាំបាច់តម្រូវដាក់ជូនចំពោះសាក្សីនោះទេ ។ យើងត្រូវតែដាក់ចំពោះមុខជនជាប់ចោទ ដែលជនជាប់ត្រូវផ្ដល់យោបល់ដើម្បីឲ្យអង្គជំនុំជម្រះអាចធ្វើការសម្រេចទៅលើបញ្ហាទាំងអស់នេះ ។ ហើយចំពោះឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដេញដោលរួចហើយនោះ ខ្ញុំបានបញ្ជាក់ កាលពីម្សិលមិញរួចហើយ ប៉ុន្តែខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់លាស់ដើម្បីកត់ត្រាទុក ។

ឧបសម្ព័ន្ធ “គ” និង“ឃ” ដែលដាក់នៅថ្ងៃទី១៩ សីហា ឆ្នាំ២០០៩ ទាក់ទងទៅនឹងចំណាររបស់ជនជាប់ចោទ ។ យើងដឹងហើយថា ឯកសារទាំងអស់នោះគឺបានដាក់នៅក្នុងសំណុំរឿង ហើយយើងបានពិនិត្យទៅលើប្រតិចារឹក តាំងពីថ្ងៃទី១៩ សីហា ២០០៩ រួចមកហើយ ។ ហើយយើងឃើញថាមានការផ្ដល់លេខឯកសារ E3 រួច ហើយ ។ ដូច្នេះហើយឆ្លើយតបទៅនឹងចៅក្រម ឡាវែន៍ នោះគឺថាយើងមិនអាចដកបានទេ ចំពោះឯកសារ ដែលមានលេខ E3 រួចហើយ ។ ប៉ុន្តែនៅពេលនេះឯកសារមួយចំនួនមិនទាន់បានផ្ដល់លេខ E3 នៅឡើយទេ ។ ដូច្នេះហើយ ដើម្បីឲ្យយើងខ្ញុំអាចជួយដល់ចៅក្រមក្នុងការចេញនូវសេចក្ដីសម្រេចទៅលើឯកសារទាំងអស់នោះ ហើយនិងដើម្បីជួយនិងផ្ដល់លទ្ធភាពឲ្យជនជាប់ចោទសរសេរចំណុច និងផ្ដល់យោបល់របស់ខ្លួនទៅនឹងឯកសារទាំងអស់នោះ ។

ដូច្នេះហើយនេះគឺជាការបញ្ជាក់បំភ្លឺរបស់ខ្ញុំ ។ ហើយប្រសិនបើខ្ញុំលើកឡើងមិនច្បាស់លាស់នោះទេ លោក លោកស្រីចៅក្រម អាចសួរបញ្ជាក់ទៅលើចំណុច ហ្នឹង ។ ហើយខ្ញុំសូមបញ្ជាក់ ភស្តុតាងទាំងអស់នេះគឺជាភស្តុតាងពាក់ព័ន្ធដោយផ្ទាល់ ។ ហើយប្រសិនបើវាជាចំណាររបស់ជនជាប់ចោទដែលមាននៅក្នុងស-២១ ហើយនោះ តើយើងអាចផ្អែកទៅលើភស្តុតាងអ្វីទៀត ដែលវាជាប់ពាក់ព័ន្ធដោយផ្ទាល់ ។

យើងឃើញហើយប្រសិនបើយើងមិនមានចម្លើយពីសាក្សីផ្សេងទៀត ឬក៏សាក្សីនៅរស់នោះទេ

យើងដឹងហើយថាវាពិបាកណាស់ដោយសារតែរយៈពេលវាកើតឡើងសាមសិបឆ្នាំរួចមកហើយ។ ដូច្នេះហើយ ខ្ញុំសូមបញ្ជាក់ថាចំណារទាំងអស់នោះគឺវាជាភស្តុតាងដោយផ្ទាល់ដែលអាចបង្ហាញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទដូចដែលគាត់បានទទួលស្គាល់ ។ នៅក្នុងច្បាប់អន្តរជាតិគឺយើងអាចពិចារណាទៅលើការសារភាពទោសផងដែរ ។ នេះជាអ្វីដែលយើងបានអនុវត្ត ។ យើងមិនចំណាយពេលច្រើនរបស់តុលាការនោះទេ យើងគ្រាន់តែបញ្ជាក់បន្ថែមទៅលើភស្តុតាងដើម្បីឲ្យគាត់ថាតើគាត់បានធ្វើ ឬក៏មិនធ្វើទៅលើការងារទាំងអស់នោះដើម្បីឲ្យយើងសន្សំពេលវេលារបស់យើង ។

[០៩:២៩:៣៣]

ដូច្នេះហើយ អ្វីដែលយើងដាក់នេះដើម្បីឆ្លើយតបនឹងផ្ទុះបញ្ចាំងអំពីអង្គហេតុផងដែរ ។ ដូច្នេះហើយ យើងដឹងហើយតុលាការនេះជាតុលាការព្រហ្មទណ្ឌហើយយើងត្រូវកត់ត្រាទៅលើអ្វីដែលវាមានកើតឡើងនៅក្នុងប្រទេសកម្ពុជាផងដែរ ។ ទាំងអស់នេះហើយជាអ្វីដែលខ្ញុំសូមបញ្ជាក់ ។

សូមអរគុណលោកប្រធាន ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដើម្បីឲ្យយើងយល់ច្បាប់ថាតើយើងយល់ច្បាស់ហើយឬនៅ? គឺថាតើមានសំណើឲ្យមានការបកប្រែជាភាសាបារាំងឬនៅ? ហើយធាតុផ្សំសំខាន់ៗនៃភស្តុតាងត្រូវបានលើកឡើងសម្រាប់ជាលក្ខខណ្ឌពិចារណារបស់តុលាការហើយឬនៅ?

**លោក អានីស អះមេដ៖**

សហព្រះរាជអាជ្ញាមិនទាន់មានសំណើនោះទេ ដោយសារតែអង្គភាពតុលាការជាអ្នកស្នើសុំឲ្យមានការបកប្រែទៅតាមសំណើរបស់ភាគីដែលគេចង់បាននោះ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សំណួរចុងក្រោយពីចៅក្រម ឡាវ៉ែន៍ គឺទាក់ទងទៅនឹងសំណើដែលធ្វើឡើងដោយមេធាវីការពារទាក់ទងទៅនឹងសេចក្ដីសង្ខេបជាភាសាបារាំងមួយទំព័រនោះ តើសហព្រះរាជអាជ្ញាមានគោលជំហរចុងក្រោយដែរឬទេអំពីសំណើនោះ?

**លោក អានីស អះមេដ៖**

គឺថាអាចនឹងធ្វើបានគឺយើងនឹងផ្ដល់ជាភាសាទាំងបីនៃតុលាការ ។ ខ្ញុំនឹងជូនក្នុងរយៈពេលមួយម៉ោង ពីរម៉ោងទៅខាងមុខនេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

[០៩:៣៣:១៨]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ សូមជម្រាបសួរ លោក លោកស្រីចៅក្រម ។ ដូច្នេះសហព្រះរាជអាជ្ញាបានប្រើពេលដប់ប្រាំនាទីដើម្បី គ្រាន់តែឆ្លើយថា បាទឬទេ? ទៅនឹងសំណួររបស់លោកចៅក្រមឡាវែន៍ ដែលទាក់ទងទៅនឹងឯកសារដែលលោកបានបញ្ជូននៅថ្ងៃទី២៩ មេសា ឆ្នាំ២០០៩ ថាតើមានការបកប្រែឬអត់? គឺដប់ប្រាំនាទី ដើម្បីឆ្លើយទៅនឹងសំណួរនោះ ។ ដូច្នេះនៅទីបំផុតនោះ អ្វីដែលយើងដឹងចុងក្រោយនោះគឺថា ទេមិនមានការបកប្រែទេ ។ ហើយលោកចៅក្រម ឡាវែន៍ បានសុំឲ្យមេធាវីការពារដើម្បីទាក់ទងជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញាដើម្បីស្វែងរកដំណោះស្រាយ ។ ហើយយើងមិនអាចធ្វើបានទៀតទេពេលនេះនោះ ពីព្រោះថា យើងមានការបញ្ជាក់ដែលថា ការបញ្ជាក់នោះមិនមានប្រយោជន៍អ្វីសោះដល់យើង ។

ដូច្នេះហើយលោកបានទម្លាក់ខ្លួនចូលទៅនៅក្នុងស្ថានភាពលើសលប់មួយ ។ អ៊ីចឹងយើងនៅក្នុងការិយាល័យរបស់យើងមានឯកសារជាច្រើនដែលទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ ។ ហើយយើងបានឮពីជម្លោះនោះ យើងមានឯកសារដ៏លើសលប់ ហើយខ្ញុំនិយាយពីរឿង នេះតាំងពីខែមករា ហើយការពិភាក្សាទាំងអស់ដែលយើងនិយាយអំពីបញ្ហាហ្នឹងជាមួយការិយាល័យសហព្រះរាជអាជ្ញានោះ ខ្ញុំទទួលស្គាល់ថា មានសេចក្តីដកស្រង់សារព័ត៌មានពីររយជាងនោះមិនត្រូវបានបកប្រែទេ ពីព្រោះនឹងត្រូវប្រើពេលច្រើន ។ ហើយខ្ញុំចង់បានតែមួយទំព័រនៃសេចក្តីបកប្រែមួយទំព័រជាភាសាបារាំងតាំងពីខែមករាមក ហេតុអ្វីបានជាមិនផលិតឯកសារនោះបាន? ខ្ញុំមិនយល់បញ្ហានេះ ។

[០៩:៣៥:១៨]

ចំណុចទីពីរ ខ្ញុំត្រូវបានបំភិតបំភ័យដោយបញ្ហានេះ ។ ខ្ញុំចង់និយាយថា ខ្ញុំមានការភ័យខ្លាចដោយសារឃើញដែលថា បង្ហាញគំនិតដោយច្បាស់លាស់នៅពេលនេះគឺនៅចុងបញ្ចប់នៃការជំនុំជម្រះ ។ ថាតើខ្ញុំអាចកំណត់បញ្ហានេះដូចម្តេចដើម្បីចៀសវាង កុំឲ្យមានលក្ខណៈដូចថាបំពានក្នុងពាក្យសម្តី ដូចជាលោកសហព្រះរាជអាជ្ញាបានប្រើពេលវេលាដោយសេចក្តីគោរពក្នុងការលើកឡើងនេះ ។

ខ្ញុំភ្ញាក់ផ្អើលគឺថាហេតុអ្វីបានជាការជំនុំជម្រះជិតនឹងចប់ទៅហើយ ហេតុអ្វីក៏សហព្រះរាជអាជ្ញា

ពឹងផ្អែកទៅលើបញ្ហាមួយដែលថាលោកនៅតែចង់ដាក់ឯកសារដេញដោលនៅតុលាការ នូវចម្លើយសារ-ភាពហុកសិបទៀត ដែលលោកមិនទាន់បានស្នើសុំឲ្យមានការដេញដោលគ្នានៅក្នុងតុលាការនេះ គឺថានូវចម្លើយសារភាពហុកសិប ។ តើលោកនិយាយថ្ងៃនេះ លោកបានចំណាយពេលប្រាំមួយខែ លោកបាននាំសាក្សី លោកបានដាក់ឯកសារហើយ នៅទីបំផុតលោកនិយាយថា សូមចាំសិនមានចម្លើយសារភាពហុកសិបទៀតដែលមិនទាន់បានលើកឡើង មិនទាន់បានដាក់ដេញដោល ។ ដូច្នេះ ខ្ញុំចង់ដាក់ជូនអង្គជំនុំជម្រះដើម្បីដេញដោលជាដុំ ទាំងមូលនេះ ។ តើពេលណាការជំនុំជម្រះនឹងចប់នៅពេលណា? តើលោករង់ចាំពេលណាឲ្យជនជាប់ចោទអាចនឹងឆ្លើយបាន?

ដូច្នេះ លោកខាងសហព្រះរាជអាជ្ញាគឺប្រើពេលពីរខែដែលនៅសេសសល់ ដែលខ្ញុំគិតថាយើងនឹងត្រូវធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ភ្លាមៗបន្ទាប់ពីសវនាការដេញដោលលើភស្តុតាងនេះ ។ ដូច្នេះ លោកនឹងត្រូវពេល លោកផ្តល់ពេលពីរខែទៀត ថាតើលោកនឹងត្រូវសរសេរសេចក្តីសន្និដ្ឋាន ១៦០ទំព័រ ទៀតដែលយើងត្រូវសិក្សាតទៅទៀត តើលោកនឹងធ្វើដូច្នេះ? ថាតើជនជាប់ចោទអាចនឹងឆ្លើយនូវសំណួរទាំងអស់ហ្នឹងនូវឯកសារដែលទម្លាក់ជូនតុលាការទាំងដុំបែបនេះដោយវិធីណាបាន?

ខ្ញុំទទួលដំណឹងនេះ ខ្ញុំរន្ធត់ណាស់ ដែលថាលោកអាចធ្វើបែបនោះបាន ហើយមានការទទួលខុសត្រូវមិនដល់កម្រិតហើយបានគ្រប់គ្រងការងាររបស់លោកមិនបានល្អ ។ ហើយសូមឲ្យលោកចៀសវាងប្រើពាក្យដែលធ្ងន់ៗពេក ។ ខ្ញុំសូមអភ័យទោសដែលខ្ញុំមានការខឹងសម្បាជាមួយបញ្ហានេះ ដែលថាវាប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ ដែលថាការស៊ើបអង្កេតមួយឆ្នាំ ការជំនុំជម្រះប្រាំបីខែ ។

[០៩:៣៨:២៩]

នៅក្នុងការជំនុំជម្រះនៅក្នុងហ្នឹង គឺជាការងាររបស់សហព្រះរាជអាជ្ញាដើម្បីលើកដាក់មកដេញដោលនូវឯកសារហុកសិបនេះ ហើយនិងឲ្យមានការឆ្លើយតបពីជនជាប់ចោទ ។ លោកសម្រេចថាមិនធ្វើដូច្នោះទេពេលនោះ ។ លោកបានសម្រេចធ្វើឲ្យយើងចំណាយពេលឲ្យគ្មានពេលដោយស្តាប់ទៅសាក្សីដែលគ្មានប្រយោជន៍ ។ ប៉ុន្តែ លោកមិនបានដកចេញពីសិទ្ធិជនជាប់ចោទមិនឲ្យធ្វើសេចក្តីសង្កេតនៅក្នុងការតទល់គ្នាដោយសេរីទៅលើឯកសារហុកសិបដែលដាក់ថ្មីនេះ ។

ខ្ញុំមើលទៅមិនឃើញថាមានលទ្ធភាពអាចនឹងបើកការជំនុំជម្រះ ឬសវនាការឡើងវិញដើម្បីនិយាយពីរឿងនេះទេ ។ ដូច្នេះយើងត្រូវនិយាយច្បាស់ទាំងអស់គ្នា អង្គជំនុំជម្រះត្រូវតែនឹងដោះលែងជនជាប់ចោទភ្លាម ហើយនិងអាចបើមិនដូច្នោះទេ ត្រូវចាប់ផ្តើមសវនាការថ្មីក្នុងរយៈពេលមួយឆ្នាំ ហើយខ្ញុំ

ដឹងថាជនជាប់ចោទត្រូវបានឃុំខ្លួនដប់ឆ្នាំមកហើយ គឺមួយថ្ងៃៗដែលកន្លងទៅគឺជាថ្ងៃនៃការឃុំខ្លួនបណ្តោះអាសន្ន គឺថាយើងមិនអាចមិនគិតពីបញ្ហានេះទេ ។ ដូច្នេះបញ្ហានេះវាសាមញ្ញ ។ មេធាវីការពារយល់ថាដំណើរការនីតិវិធី ហើយនិងការដេញដោលវាចប់ទៅហើយ ។

ហើយសហព្រះរាជអាជ្ញាមិនអាចដាក់ឯកសារសូមដេញដោលជាងហុកសិបទៀតនោះទេ ។ ហើយឧបសម្ព័ន្ធ “គ” និង “ឃ” ដូច្នេះខ្ញុំ តើឧបសម្ព័ន្ធ “គ” នោះនៅកន្លែងណា? ខ្ញុំមិនឃើញទេ ។ ហើយនៅក្នុង E152 អ្វីដែលខ្ញុំមាននោះគឺជាឧបសម្ព័ន្ធ “ឃ” តើលោកចង់និយាយដូចម្តេច? នៅពេលដែលលោកនិយាយថា ឧបសម្ព័ន្ធ “គ” នោះ?

លោកប្រធាន លោក លោកស្រីចៅក្រម ក្នុងនាមមេធាវីការពារ គឺឯកសារមួយសំណុំ ទាំងដុំអ៊ីចេះ គឺមិនគប្បីទទួលស្គាល់យកមកដេញដោលទេ ពីព្រោះថាមិនដាក់ទាន់កាលវេលា ។ បើសិនជាតុលាការសម្រេចថា ដាក់ដេញដោលចំពោះតុលាការនោះ ខ្ញុំសូមថា សូមឲ្យបើកនីតិវិធីទាំងស្រុងឡើងវិញ ហើយជនជាប់ចោទ នឹងត្រូវបានដោះលែងភ្លាមផងដែរ ។

[០៩:៤១:០២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក អានីស អះមេដ៖**

ខ្ញុំសូមរយៈពេលបន្ថែមបន្តិចទៀត ហើយខ្ញុំមិនប្រើពេលវែងហើយខ្ញុំនឹងមិនប្រើភាសាធ្ងន់ធ្ងរទេ។ មេធាវីបានលើកឯកសារតម្កល់ ១៩ ខែសីហា គឺថាលោកមានឯកសារឧបសម្ព័ន្ធ “ឃ” ចំពោះមុខលោកនេះជាចំណុចទីមួយ ។ ចំណុចទីពីរ លោក លោកស្រីចៅក្រម បានប្រកាសនៅថ្ងៃ៣១ សីហា ២០០៨ នីតិវិធីមិនទាន់ចប់នោះទេ ។ យើងបានរក្សាទុកមួយថ្ងៃពីរថ្ងៃចុងក្រោយនេះ នេះគឺជាការកំណត់ពេលដ៏ល្អដែលអនុញ្ញាតឲ្យភាគីដាក់ឯកសារដេញដោល ដើម្បីបញ្ចប់កំណត់ត្រា ដំណើរការនីតិវិធីដើម្បីប្រជុំសម្រេចលើសាលក្រម ។

ឯកសារទាំងនេះ បានស្ថិតនៅក្នុងសំណុំរឿងរួចហើយ យើងមិនសុំឲ្យមេធាវីការពារឲ្យឆ្លើយតបទៅនឹងសវនាការសាធារណៈថ្ងៃនេះ ឬក៏ម្សិលមិញនោះទេ ។ យើងបានដាក់សំណើហ្នឹងថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ គាត់មានពេលមួយខែដើម្បីឆ្លើយតបនូវចំណុចទាំងអស់នេះ ហើយឆ្លើយជាលាយលក្ខណ៍អក្សរ ។ ហើយគាត់ដឹងថា នៅថ្ងៃ៣១ សីហា អង្គជំនុំជម្រះបានផ្តល់ពីរបីថ្ងៃ ដើម្បីទទួលនូវការ

ឆ្លើយតប សារណាតប មិនមែនឲ្យឆ្លើយនៅក្នុងសវនាការដែលខ្លួនមិនបានផ្តល់ជាលាយលក្ខណ៍អក្សរ បើខ្លួនមិនបានឆ្លើយតបទេ មិនមិនបញ្ហាទេ ពេលនោះអង្គជំនុំជម្រះអាចសម្រេចបាន ប៉ុន្តែមេធាវីការពារមិនបាននិយាយថាខ្លួនបានពន្យារពេលដោយសារមិនបានដាក់ក្នុងរយៈពេលមួយខែពីមុន ហើយខ្លួនមិនបានឆ្លើយតបនោះ ។

[០៩:៤៣:០៨]

ចំណុចទីបី ដែលជាសំណើដ៏សំខាន់បំផុតទាក់ទងទៅនឹងអង្គជំនុំជម្រះ នេះគឺជាទម្លាប់អនុវត្តធម្មតារបស់សាលាក្តីអន្តរជាតិ នៅពេលដែលចុងបញ្ចប់នៃការជំនុំជម្រះ ដែលពេលមានសារណាពីពិរុទ្ធភាពនោះ គឺថា ភស្តុតាងទាំងអស់ដែលគាំទ្រការសារភាពនោះទទួលស្គាល់ដោយភាគីទាំងអស់ដើម្បីបំពេញសំណុំរឿងក្តីនេះ ។ ប៉ុន្តែខ្ញុំឃើញថា អាចនឹងមានការអះអាងត្រឹមត្រូវរបស់មេធាវីការពារដែលលោកលើកឡើងថា គប្បីដាក់ថាវត្ថុតាងទាំងអស់នេះក្នុងវេបសាយ នេះជាចំណុច គឺថាមិនមែនតែ-- តើយើងត្រូវដាក់សេចក្តីសារភាពហ្នឹងរបស់ ឌុច នៅក្នុងវេបសាយ តើឯកសារអ្វីៗទៀតដែរឬទេ? បើមិនដាក់ឯកសារទាំងអស់ហ្នឹងទេ គឺថាយុត្តិធម៌មិនបានបង្ហាញឲ្យមានតម្លាភាពឲ្យស្របតាមច្បាប់នោះទេ ។

សាក្សីទាំងឡាយដែលបាននាំមកចំពោះមុខតុលាការនេះ ត្រូវបានអង្គជំនុំជម្រះកោះអញ្ជើញ ។ សហព្រះរាជអាជ្ញាមិនឃើញថា មានការបដិសេធនូវសាធារណៈថា ជាការចំណាយពេលឥតប្រយោជន៍នៅក្នុងសាធារណៈនោះទេ ។

ហើយនៅចំណុចទីបី លោក លោកស្រីចៅក្រមបានដឹកនាំនីតិវិធីនេះ គឺជាការជំនុំជម្រះដែលមានកត់ត្រាសំឡេងនិងរូបភាព ហើយដូច្នេះយើងប្រើពេលដប់ប្រាំមីនុត ដប់ប្រាំនាទីសម្រាប់កន្លះថ្ងៃ ។ អ៊ីចឹងហើយ គឺទាក់ទងអំពី-- ដើម្បីតួនាទីរបស់ព្រះរាជអាជ្ញា ដើម្បីបង្ហាញភស្តុតាងឲ្យហួសពីវិមតិសង្ស័យនោះ គឺថានេះគឺជាភស្តុតាងមួយ ដែលទាក់ទងផ្ទាល់ ដែលត្រូវតែដាក់ដេញដោល ។ តើការជំនុំជម្រះអាចនឹងវែងនឹងទេ? គឺថា ប៉ុន្តែវាអាចនឹងវែង ប៉ុន្តែមិនទៅរួចទេ ដោយហេតុថាគាត់ទទួលសារភាពពិរុទ្ធភាពនោះហើយ ។ យើងត្រូវតែដាក់ឯកសារដើម្បីឲ្យវាមានលក្ខណៈពេញលេញ ហើយអង្គជំនុំជម្រះហ្នឹងត្រូវធ្វើសេចក្តីសម្រេចឲ្យបានត្រឹមត្រូវ ដោយផ្ទៀងផ្ទាត់រវាងភស្តុតាង ហើយនិងការសារភាពពិរុទ្ធភាពរបស់គាត់ ។ ហើយខ្ញុំមិនមានអ្វីទាមទារលើសពីហ្នឹងទៀតទេ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

[០៩:៤៥:៣២]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមគោរពលោកប្រធាន ខ្ញុំអាចទទួលស្គាល់ថាៗ មេធាវីការពារក៏ត្រូវតែឆ្លើយតប វាមានវិធាន ដែលវិធាន ដែល-- ហើយក៏ភាគីទាំងអស់មានការណែនាំដែលយើងត្រូវឆ្លើយតបទៅតាមហ្នឹងក្នុងរយៈពេលប្រាំថ្ងៃ ឬដប់ប្រាំថ្ងៃ ឲ្យមានអត្ថបទបកប្រែជាភាសាបារាំង នូវសំណើរបស់លោកដែលជាសំណើចុះថ្ងៃទី២៩ សីហា ដែលត្រូវបកប្រែទៅជាភាសាបារាំង ហើយឯកសារទាំងអស់ដែលបានបញ្ជូនមកខ្ញុំនុំងមិនត្រូវបានបកប្រែទៅជាភាសាបារាំងនៅឡើយទេ ។ តើលោករំពឹងឲ្យខ្ញុំឆ្លើយតបដូចម្ដេចនឹងបាន? ហើយលោកបានចង្អុលបង្ហាញថា លោកខ្លួនឯងពិតមានឯកសារនេះគឺតាំងពីចាប់ផ្ដើមដំណើរការនីតិវិធី តើលោកអាចពន្យល់ដល់អង្គជំនុំជម្រះបានដែរឬទេ? ហេតុអ្វីបានជារង់ចាំរហូតដល់ថ្ងៃទី២៩ ខែសីហា ដើម្បីនឹងដាក់ជូនឯកសារទាំងនេះនោះ? លោកបានជ្រើសរើសតាំងពីចាប់ផ្ដើមរឿងក្ដីដែលលោកដឹងថានឹងប្រើឯកសារនេះ ហើយលោករង់ចាំរហូតមកដល់ថ្ងៃទី២៩ ខែសីហា ដើម្បីដាក់ជូនអង្គជំនុំជម្រះដេញដោលនោះ ។ តើលោករំពឹងឲ្យការបកប្រែនោះថានឹងបកបានដូចម្ដេច?

[០៩:៤៧:១២]

ដូច្នេះ នៅពេលដែលខ្ញុំទទួលសំណើហ្នឹងជាភាសាបារាំង ខ្ញុំត្រូវមានប្រាំ ឬក៏ដប់ប្រាំថ្ងៃ ដើម្បីឆ្លើយតប ហើយខ្ញុំនឹងត្រូវរង់ចាំសំណើហ្នឹងធ្វើជាភាសាបារាំងនោះដែរ ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាគួរតែត្រូវបានសរុបនូវគំនិតទាំងអស់ ហើយលោកនិយាយនេះគឺកំណត់ថាបញ្ហានេះជាលើកចុងក្រោយហើយ ដើម្បីឲ្យបញ្ហាវាចប់ពីព្រោះពីម្សិលមិញរហូតដល់ពេលនេះ ដូចជាការវិលវល់នៃការពិភាក្សាហ្នឹងគឺ ហាក់ដូចជាមិនចេញឆ្ងាយពេកពីអ្វីដែលវាមានការជជែកពិភាក្សាកាលពីម្សិលមិញទេ ។

អ៊ីចឹងគឺក្រៅពីអ្វីដែលថ្មី គឺសូមឲ្យលោកសរុប ដើម្បីឲ្យន័យបានចប់គឺត្រឹមតែលើកនេះ ហើយមិនមានការតទេ គឺតវិញដោយខាងមេធាវីការពារក្ដី អានេះជារឿងចុងក្រោយ ។

**លោក អានីស អះមេដ៖**

សូមគោរពលោកប្រធាន! លោកដូចដឹងចិត្តខ្ញុំ ហើយខ្ញុំមិនចង់និយាយអ្វីច្រើនទៀតទេ ។ ខ្ញុំសូមកែតម្រូវលោកមេធាវីការពារមិនមែនថ្ងៃ ២៩ ខែសីហា ទេ គឺមិនមានអ្វីថែមទៀតទេ គឺថ្ងៃទី១៩ ខែ

សីហា ឆ្នាំ២០០៩ តែប៉ុណ្ណឹងបាទ ។

[០៩:៤៨:៥០]

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម មានអ្វីបញ្ជាក់ពីបញ្ហានេះទៀតទេ? បើមិនមានទេ សូមលោកអញ្ជើញមេធាវីការពារក្ដីបញ្ជាក់សាជាថ្មីម្ដងទៀត កាលពីម្សិលមិញគឺលោកបានលើកឡើងអំពីការស្នើសុំដាក់ឯកសារមួយដែលតាមការដែលខ្ញុំនៅចងចាំកាលពីម្សិលមិញ តើលោកនៅតែប្រកាន់ជំហរក្នុងការសុំដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះដែរឬទេ? ដើម្បីឲ្យភាគីផ្សេងទៀតហ្នឹងបានធ្វើការសង្កេត ឬក៏កត់សម្គាល់ការដាក់ឯកសារភាគីមេធាវីការពារក្ដីផង ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ មេធាវីការពារបានដាក់ជូននូវឯកសារមួយចំនួនទៅសហចៅក្រមស៊ើបអង្កេត D80 ឯកសារមួយ ហើយមេធាវីការពារសូមអនុញ្ញាតឲ្យដាក់ឯកសារនេះចាត់ទុកថាដាក់ដេញដោលចំពោះមុខអង្គជំនុំជម្រះរួចហើយ ។ ហើយខ្ញុំនឹងរៀបជាបញ្ជីលំដាប់លំដោយជូន D80/1 សៀវភៅដែលមានចំណងជើងថា "ប៉ុល ពត គឺសុបិនដ៏អាក្រក់" ដែលសរសេរឡើង ហ្វីលីព សត ដែលមានជាភាសាបារាំងនិងភាសាអង់គ្លេស ហើយត្រូវបានដាក់ចូលនៅក្នុងសំណុំរឿង ដោយហេតុថា យើងបានដាក់ទៅសហចៅក្រមស៊ើបអង្កេត ។ ហើយនិង D80/2 យើងពិនិត្យឃើញថា សៀវភៅរបស់ដេវីដ ឆេនឌ័ល័រ អំពីស-២១ ជាអត្ថបទជាភាសាបារាំង និងអង់គ្លេសផងដែរ ។ D80/4 សៀវភៅរបស់ ហ្វ្រង់ស្វ័រ ប៊ីហ្សូត ដែលបានលើកមកនិយាយនៅដំណើរជំនុំជម្រះហើយ គឺឈ្មោះថា "ឡឺ ព័កតៃ" គឺឃ្លោងទ្វារធំ ហើយនិងសៀវភៅឯកសារមួយទៀត D80/50 សៀវភៅរបស់លោក វ៉ាអ៊ីល ម៉ាកចេនណា ដែលយើងបានលើកមកដេញដោលនៅក្នុងការពិភាក្សារួចហើយ ហៅថា "ឡឺ ក្លេ ឌុយ កាំបូដស៍" មានន័យថា កូនសោឆ្ពោះកម្ពុជា ។

D80/6 សៀវភៅរបស់ ហ្វ្រង់ស្វ័រ ប៉ុងសូ ដែលមានចំណងជើងថា "កាំបូដស៍ អាន់ណេ ហ្សេរ៉ូ" កម្ពុជាឆ្នាំសូន្យ អត្ថបទភាសាបារាំងហើយនិងជាភាសាខ្មែរ ។ នៅក្នុងបញ្ជីដដែលនេះដែរ នៃបញ្ជីវត្ថុតាងដែលយើងបានដាក់ជូនទៅសហចៅក្រមស៊ើបអង្កេតនោះ ឯកសារ D88 យើងបានដាក់បញ្ចូលនូវផែនទីដែលទទួលបានពីអង្គការ *ឌីស៊ីខេម* D80/9 ជារូបភាពថតតាមផ្កាយរណបដែលទទួលបានពីអង្គការ *ឌីស៊ីខេម* ហើយនិង D80/10 គឺមានឯកសារផែនទីផ្សេងទៀតអំពីរណ្ដៅសពរួមនៅក្នុងកម្ពុជា

ក៏ជាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ។ ហើយឯកសារទាំងបីចុងក្រោយនេះ ត្រូវបានដាក់ដេញដោលចំពោះមុខអង្គជំនុំជម្រះរួចហើយនៅពេលដែលលោក វ៉ាអ៊្វល ម៉ាកចេនណា បានមកផ្តល់សក្ខីកម្មចំពោះមុខតុលាការនេះ ។

[០៩:៥៣:៤១]

បន្ទាប់មក យើងខ្ញុំសូមស្នើឲ្យមានការអនុញ្ញាតឲ្យដាក់ឯកសារថ្មីមួយចំនួន ដែលមាន E5/9 ហើយយើងទទួលបានពីគំនិតដំបូងនោះ គឺថាពីដំបូងនៃដើមដំណើរការនីតិវិធីនោះឯកសារ គឺយើងមាននិយាយអំពីសៀវភៅរបស់លោក ហេនរី យើង ជាសាក្សីដែលមិនមានលទ្ធភាពបង្ហាញខ្លួនបាន ដោយហេតុថាគាត់បានទទួលមរណភាព ។ សៀវភៅរបស់ ប៊ូក ហេនរី យើង នោះគឺមានចំណងជើងថា "ដឺ ធូវ៉ឺល អហ្វ អាល់ប៊ឺតស្តៀ" ដែលមានន័យថា ពិភពលោកពីររបស់ អាល់ប៊ីស្តែរ ។ ទាក់ទងនឹងបញ្ហានេះ ខ្ញុំសូមរំឭកដល់អង្គជំនុំជម្រះថា យើងខ្ញុំស្នើសុំដាក់ជូនសៀវភៅនេះ ពីព្រោះថាសៀវភៅនោះក៏មានត្រូវៗបញ្ចូលក្នុងសំណុំរឿង ។ ខ្ញុំនឹងពិនិត្យ ហើយយើងមានដាក់ចូលមួយទៀតជាសំបុត្រដែលជាសេចក្តីថ្លែងអះអាងបញ្ជាក់ដែលដាក់រួមជាមួយថា ជាសាក្សីជំនួស ពាក្យសក្ខីកម្មរបស់គាត់ដែលមិនបានផ្តល់នោះ គឺ E5/9/2 ។

នៅក្នុងបញ្ជីនេះផងដែរ E5/9 ហើយយើងខ្ញុំស្នើការអនុញ្ញាតដើម្បីដាក់ដេញដោលចំពោះមុខតុលាការនូវប្រតិចារឹកនៃការសវនាការថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៣ នៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ដែលទាក់ទងទៅនឹងនិយាយអំពីសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាក្នុងរឿងក្តី *អុប្រ៊េណូវិច* ហើយនិងឯកសារវីដេអូ ហើយនិងសោតទស្សន៍ ដែលជាសេចក្តីដកស្រង់នៃសវនាការនោះ ត្រង់ចំណុចនោះ ហើយនិងសាលក្រមដែលបានចេញដោយសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៅអតីត *យូហ្គោស្លាវី* នៅថ្ងៃទី១០ ធ្នូ ២០០៣ ក្នុងរឿងក្តី *អុប្រ៊េណូវិច* ។

ខ្ញុំសូមបញ្ជាក់ពីអង្គហេតុដែលថា គឺជាទម្លាប់មួយថាយើងមិនចាំបាច់បញ្ជូនទៅវិញទៅមកនូវសេចក្តីសម្រេចរបស់តុលាការនោះទេ គឺថាយើងត្រូវតែជម្រាបឲ្យច្បាស់ ដើម្បីធានានូវតម្លាភាព ។ ដូច្នេះគឺថានៅក្នុងបញ្ជីប្រាំដល់ប្រាំបួននេះ ហើយយើងសូមស្នើសូមដាក់សៀវភៅ *ដេសមិន ទូទូ* ដើម្បីដេញដោល-- ថាបានដេញដោល ដោយសារយើងបាននិយាយដល់ភាគច្រើនបញ្ហាហ្នឹងនៅក្នុងសវនាការកាលពីមុន ខ្ញុំមានជាភាសាបារាំង និងភាសាអង់គ្លេស ។

តាមពិត មេធាវីការពារចង់បន្ថែមឯកសារទាំងអស់នេះដើម្បីធ្វើការបញ្ជាក់ផ្ទៀងផ្ទាត់ឲ្យបានច្បាស់

ថា ការទទួលស្គាល់នូវអង្គហេតុទាំងនោះត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះ ហើយយើងមានឯកសារដែលយើងមាន E3 នៅក្នុងឯកសារ ហើយសុំឲ្យមានការបញ្ជាក់ ហើយបញ្ជាក់អំពីអង្គហេតុហើយខ្ញុំនឹងអរគុណ ប្រសិនបើក្រឡាបញ្ជីអាចបញ្ជាក់ថា ការទទួលស្គាល់នូវអង្គហេតុហ្នឹងគឺពិតជាៗបានដាក់ដេញដោលចំពោះមុខតុលាការដែរឬទេ? ហើយខ្ញុំបានបញ្ជាក់ពីម្សិលមិញគឺថាមានឯកសារមួយ គឺជាឯកសារដែលដាក់ចុងក្រោយបន្ទាន់មួយ គឺជាបទសម្ភាសន៍ដែលផ្តល់ឡើងដោយលោក ជុំ ម៉ី ដែលបានបញ្ជាក់ទៅឲ្យអ្នកកាសែតបារាំង គឺជាឯកសារមានមួយទំព័រ ហើយយើងបានទទួលបានជាភាសាបារាំងនិងខ្មែរ ហើយនិងបញ្ជូនទៅខាងសហព្រះរាជអាជ្ញា ដូចដែលបានបញ្ជាក់ ។ ប៉ុន្តែ យើងមិនមានចេតនាថា ដាក់ឯកសារនេះមុនពេលមានការអនុញ្ញាតដើម្បីបង្ហាញនូវវីដេអូត្រង់ចំណុចនោះទេ ដែលយើងបានបង្ហាញពីម្សិលមិញនេះជាឯកសារ ដែលមេធាវីមានបំណងចង់ឲ្យដាក់បញ្ចូលទៅក្នុងឯកសារដែលជាផ្នែកដែលបានដាក់ដេញដោលចំពោះមុខអង្គជំនុំជម្រះ ។

ខ្ញុំក៏បានគិតឃើញអំពីការពិគ្រោះយោបល់អំពីលោក វ៉ាអ៊ូល ម៉ាកចេនណា D80 គឺD82 យើងនឹងត្រូវធ្វើការបញ្ជាក់ផ្ទៀងផ្ទាត់ចំណុចនេះផងដែរ ។ ខ្ញុំចប់ប៉ុណ្ណឹងលោកប្រធាន ។

[០៩:៥៩:៤៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រមហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះរំឭកថា រំឭកដល់ភាគីថ្មីៗនេះថា ទាក់ទងទៅនឹងការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះៗ ចង់ដឹងអំពីមូលហេតុឲ្យបានច្បាស់លាស់ ហេតុអ្វីបានជាឯកសារទាំងអស់នោះគួរតែដាក់នៅចំពោះមុខអង្គជំនុំជម្រះរបស់យើង ។ ជាពិសេស សៀវភៅមួយចំនួនគឺបានដាក់មកចូលចំពោះមុខអង្គជំនុំជម្រះហើយ សៀវភៅមួយចំនួនទៀតមិនទាន់ដាក់នៅឡើយទេ ។ ដូច្នេះហើយមេធាវីការពារក្តីគួរតែផ្តល់មូលហេតុថា ហេតុអ្វីបានជាខ្លួនមានបំណងក្នុងការដាក់សៀវភៅនោះមួយចំនួន ដោយសារតែសៀវភៅមួយចំនួននោះវាមានលក្ខណៈ មានទំព័រច្រើនណាស់ ហើយមេធាវីការពារក្តីគួរតែបញ្ជាក់ ថាហេតុអ្វីបានជាខ្លួនមានបំណងដាក់សៀវភៅទាំងអស់នោះនៅចំពោះសវនាការនិងអង្គជំនុំជម្រះរបស់យើង?

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកចៅក្រមជាទីគោរព! ជាការពិតឯកសារទាំងអស់យើងបានពិភាក្សាដេញដោលគ្នានៅក្នុងសវនាការរបស់យើងហើយ ជាពិសេសនៅពេលដែលយើងដេញដោលទៅលើសាក្សី ហើយខ្ញុំគិតពិចារ-ណាទៅលើសៀវភៅរបស់លោក ដេវីដ ឆេនដ័ល័រ ។ សៀវភៅរបស់លោក ប៊ីហ្ស និងសៀវភៅរបស់លោក វ៉ាអ៊ីល ម៉ាកចេនណា ។ ខ្ញុំគិតឃើញថា វាមិនមានការលំបាកទេទៅលើស្នាដៃសៀវភៅរបស់គាត់នោះ ដោយសារតែសៀវភៅ ឬក៏ស្នាដៃទាំងអស់នោះ គឺវាគ្រាន់តែបញ្ជាក់ទៅលើចម្លើយរបស់អ្នកទាំងឡាយនោះ ដែលបានមកផ្ដល់សក្ខីកម្មនៅចំពោះមុខតុលាការរបស់យើងតែប៉ុណ្ណោះ ។

ចំពោះសៀវភៅរបស់លោក *ដេសមិន ទូទូ* យើងបានពិភាក្សាជាមួយនឹងសាក្សីមួយហើយ ។ សៀវភៅមួយនេះគឺវាមានធាតុផ្សំ និងសម្ភារៈមួយចំនួនដែលមេធាវីការពារក្ដីមានបំណងយកមកធ្វើជាមូលដ្ឋាន ។ សាក្សីមួយយើងបានសួររួចហើយ ទាក់ទងទៅនឹងសៀវភៅនេះ ដូច្នេះហើយការយល់ឃើញរបស់ខ្ញុំ សៀវភៅនេះមិនបង្កជាការលំបាកនោះទេ ។ យើងមិននិយាយអំពីសៀវភៅដែលមានចំណងជើងថា “កាំបូដស៍ អាន់ណេ ហ្សេរ៉ូ” សរសេរដោយ ហ្វ្រង់ស្វ័រ ប៉ង់សូ ហើយនិងសៀវភៅប៉ុល ពត *“អាន់ណាតូមី អហ្វ ណាយមែរ”* គឺយើងមិនសូមលើកឡើងទៅលើសៀវភៅនេះទេ ។

[១០:០២:៤២]

មេធាវីការពារក្ដី មានបំណងក្នុងការពិចារណាទៅលើស្នាដៃសៀវភៅទាំងអស់នោះ ដើម្បីយកមកគាំទ្រជាមូលដ្ឋាន នៅពេលដែលខ្លួនធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ ។ យើងមិនលើកឡើងទៅលើសៀវភៅទាំងអស់ ឬក៏ព័ត៌មានទាំងអស់នៅក្នុងសៀវភៅនោះទេ ។ មេធាវីការពារក្ដីលើកតែចំណុចជាក់លាក់មួយចំនួនតែប៉ុណ្ណោះនៅក្នុងសៀវភៅ ។ ខ្ញុំសូមបញ្ជាក់ថា ជាពិសេសនៅក្នុងសៀវភៅ ហ្វីលីព សត គឺយើងខ្ញុំជាមេធាវីការពារក្ដីបានពិចារណាថាឲ្យកោះហៅ ហ្វីលីព សត មកធ្វើជាសាក្សី ។ ប៉ុន្តែ ដើម្បីកុំឲ្យបន្ទាយនីតិវិធីរបស់យើង មេធាវីការពារក្ដីសម្រេចថា មិនកោះទៅវិញ ។ ជាពិសេសយើងពិចារណាថាសៀវភៅនោះបានដាក់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតរួចហើយ ។ ដូច្នេះហើយវាគ្រប់គ្រាន់ហើយ ក្នុងការដែលយើងអាចយោងទៅលើអត្ថបទមួយចំនួយនៅក្នុងសៀវភៅនោះ ។

ដូច្នេះចំណុចទាំងអស់នេះ គឺអ្វីដែលខ្ញុំលើកឡើងទាក់ទងទៅនឹងសៀវភៅនេះ ហើយខ្ញុំគិតថាសៀវភៅផ្សេងទៀត គឺផ្ដល់ឲ្យ អនុញ្ញាត ឬក៏តម្រូវឲ្យយើងខ្ញុំផ្ដល់ជាយោបល់នោះទេ។ វាជាយុត្តិសាស្ត្រដូច្នេះហើយមេធាវីការពារក្ដីអាចមានលទ្ធភាពផ្ដោចទៅលើ ឬក៏យកយុត្តិសាស្ត្រទាំងអស់នោះមកធ្វើជា

មូលដ្ឋាន ។

ហើយចំពោះខ្សែវីដេអូនៅក្នុងសវនាការ យើង-- វាមានភាពងាយស្រួលក្នុងការបង្ហាញនូវខ្សែរូបថត ខ្សែវីដេអូ ដែលថាអាចនឹងបញ្ចាំងនៅក្នុងពេលដែលខ្ញុំធ្វើសេចក្តីសន្និដ្ឋានបញ្ចប់របស់ខ្ញុំ ជាជាងការពិនិត្យទៅលើប្រតិចារឹកនៃសវនាការនោះ ។ នេះជាចំណុចដែលខ្ញុំចង់លើកឡើង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំចង់ឲ្យបំភ្លឺចំណុចទាំងអស់នេះ ដើម្បីជាប្រយោជន៍ទៅដល់អង្គជំនុំជម្រះសាលាដំបូងរបស់យើង។ ដូច្នេះ ឯកសារសៀវភៅទាំងអស់នោះមិនមែនជាភស្តុតាងថ្មីនោះទេ អ្វីដែលយើងចាប់អារម្មណ៍នោះគឺទាក់ទងទៅនឹងភស្តុតាង ។ លោកបាននិយាយថា លោកមានបំណងក្នុងការយកឯកសារទាំងអស់នោះមកធ្វើជាមូលដ្ឋានដើម្បីគាំទ្រទៅនឹងរឿងក្តីរបស់លោក ។ ដូច្នេះហើយវាមិនមែនជាភស្តុតាងទេ ។

ដូច្នេះថាតើ បើសិនជាមិនមែនជាភស្តុតាងនោះ តើវាជាឯកសារសម្ភារៈអ្វី ហើយយើងកំពុងតែលើកឡើងទៅលើចំណុចអ្វីខ្លះ?

[១០:០៥:១៥]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកចៅក្រម! គឺលោកចៅក្រមលើកសំណួរនេះត្រឹមត្រូវ ។ ទាំងអស់នោះមិនមែនជាភស្តុតាងថ្មីនោះទេ វាគ្រាន់តែជាការបង្ហាញ ឯកសារបង្ហាញទៅលើអង្គហេតុដែលយើងបានពិភាក្សាគ្នារួចហើយនៅក្នុងសវនាការរបស់យើង ដែលថាយើងនឹងអាចយកសម្ភារៈ ឬក៏ព័ត៌មានទាំងអស់នោះមកធ្វើជាមូលដ្ឋាន ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីធ្វើការអង្កេតលើសំណើសុំដាក់ឯកសារចាត់ទុកថាជាឯកសារពិភាក្សាដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ នូវឯកសារមួយចំនួនដែលមានជាសៀវភៅ ឬក៏ជាឯកសារផ្សេងៗ ដែលលើកឡើងដោយមេធាវីការពារក្តីអម្បាញ់មិញនេះ ។

**លោក អានីស អះមេដ៖**

ដូចដែលខ្ញុំជម្រាប ខ្ញុំនឹងនិយាយនិងលើកសេចក្តីអង្កេតរបស់ខ្ញុំដោយខ្លីៗ ។ មេធាវីការពារក្តីគាត់មានបទពិសោធន៍ហើយចូលរួមនៅក្នុងសវនាការនេះ រយៈពេលកន្លះឆ្នាំមកនេះ ហើយនៅក្នុងសេចក្តីដាក់ឯកសាររបស់យើង យើងប្រយ័ត្នទៅលើពាក្យដែលយើងប្រើ ។ ពាក្យមួយនោះគឺដូចដែលលោកចៅ

ក្រុម ឡាវែន៍ បានលើកហើយ គឺវាទាក់ទងទៅនឹងភស្តុតាង ហើយពាក្យមួយទៀតគឺ "យថាភាព" ដែលវាគាំទ្រទៅលើសេចក្តីសន្និដ្ឋាន ដែលវាលើកឡើងដោយភាគីនៅក្នុងការសន្និដ្ឋានបញ្ចប់ ហើយយើងអាចដាក់បាន យើងអាចបញ្ចូលទៅក្នុងសំណុំរឿង ប៉ុន្តែយើងមិនអាចយកមកចាត់ទុកថាវាជាភស្តុតាងនោះទេ ។

យើងខ្ញុំសូមបញ្ជាក់ថា វិធាន ៨៧.២ និង៣ គឺវាចែងទាក់ទងទៅនឹងភស្តុតាង មិនមែនទាក់ទងទៅនឹងឯកសារយោងរបស់តុលាការនោះទេ ។ មេធាវីការពារក្តីដែលគាត់ចំណាយដប់ប្រាំ និងម៉្ភៃនាទីគាត់ប្រើពាក្យថា "ដាំធំ" បានន័យថា "ចាក់បង្ហូរឯកសារជាច្រើនចូលតុលាការនេះ" ដោយមិនបានដាក់សំណើសង្ខេបដើម្បីបញ្ជាក់អំពីហេតុផលថាហេតុអ្វីបានជាចង់ដាក់សៀវភៅទាំងអស់នេះ ។ សហព្រះរាជអាជ្ញា យើងខ្ញុំមិនមានការជំទាស់ទៅលើសៀវភៅ ដេវីដ ឆេនដ៍ល័រ, ប៊ីហ្ស នោះទេ ដោយសារតែអ្នកទាំងពីរនោះគាត់មកដេញដោលជាសាក្សីរួចហើយ ហើយយើងខ្ញុំគោរពទទួលយកសៀវភៅទាំងពីរនោះនៅចំពោះមុខអង្គសវនាការរបស់យើង ។

[១០:០៨:០១]

ប៉ុន្តែមិនមានការឆ្លុះបញ្ចាំងនៅក្នុងប្រតិចារឹក ដែលថាមេធាវីការពារក្តីបង្ហាញចង់ស្នើសុំ ហ្វីលីពសត មកចូលក្នុងតុលាការនោះទេ ហើយយើងបាន-- ហើយមេធាវីការពារក្តីមិនស្នើសុំទៅអង្គជំនុំជម្រះក៏ដូចជាសហចៅក្រមស៊ើបអង្កេតនោះផងដែរ ។ មូលហេតុដែលយើងបានស្នើសុំដាក់សៀវភៅ នីក ដងឡុប ដោយសារតែយើងខ្ញុំបានស្នើសុំឲ្យគាត់មកធ្វើជាសាក្សី ។ ប៉ុន្តែ អង្គជំនុំជម្រះមិនទទួលយកហើយបញ្ហានេះ-- បញ្ហាសៀវភៅរបស់ នីក ដងឡុប គឺបានយកមកដេញដោល ដូច្នេះហើយយើងគួរថាវាអាចយកមកពិចារណាជាភស្តុតាង ។ ដូច្នេះហើយយើងខ្ញុំសូមលើកឡើងថា សៀវភៅរបស់ ហ្វីលីពសត មិនគួរដាក់នៅក្នុងសំណុំរឿងនោះទេ ។ យើងខ្ញុំសូមលើកឡើងថា សៀវភៅរបស់ ដេវីដ ឆេនដ៍ល័រហើយលោក ដេវីដ ឆេនដ៍ល័រ លើកឡើងថា សៀវភៅច្បាប់ដើមរបស់គាត់គួរតែយកជាភាសាអង់គ្លេស។ ដូច្នេះហើយយើងគួរតែទទួលយកសៀវភៅនោះជាភាសាអង់គ្លេស ហើយយើងក៏ទទួលយកសៀវភៅរបស់លោក វ៉ាអ៊ួល ចេនណា ក៏ដោយ ទោះបីជាវាមានការពាក់ព័ន្ធដោយប្រយោលទៅលើស-២១ ក៏ដោយ ហើយយើងខ្ញុំសូមដាក់ជូនថាសៀវភៅ ប៉ង់សូ មិនគួរដាក់ចូលទៅក្នុងសំណុំរឿងនោះទេ ដោយសារតែសៀវភៅនោះ វាមិនផ្តល់ជាប្រយោជន៍ជួយទៅដល់អង្គជំនុំជម្រះនោះទេ ។ ដូច្នេះហើយយើងគួរតែពិចារណាទៅតាមវិធាន ៨៧(ក)-- ៣(ក)-- ៨៧.៣(ក) ដែលវាជាឯកសារជាន់គ្នា ។

[១០:០៩:៤៤]

ទាក់ទងទៅនឹងបញ្ហាផែនទី មេធាវីការពារក្តីបានយោងទៅលើផែនទីនោះ ប៉ុន្តែគាត់មិនដែលស្នើសុំដាក់ផែនទីនោះនៅក្នុងសំណុំរឿងនោះទេ ហើយមិនបានពិភាក្សាដេញដោលនៅចំពោះមុខសហចៅ ឬក៏នៅចំពោះអង្គជំនុំជម្រះនេះទេ ។ ដូច្នេះហើយយើងមិនដឹងថា ផែនទីនោះវាពាក់ព័ន្ធយ៉ាងម៉េច? ហើយនិងគោលគំនិតដែលមេធាវីការពារក្តីចង់ទាញប្រយោជន៍ពីផែនទីទាំងអស់នោះ ។ យើងឃើញហើយថា ផែនទីនោះ យើងឃើញថាវាជាផែនទី ហើយយើងនៅចុងសវនាការហើយ ដូច្នេះហើយវាអាស្រ័យទៅលើអង្គជំនុំជម្រះទៅលើបញ្ហានៃផែនទី ។

ហើយចំពោះចម្លើយសេចក្តីការរបស់ ហេនរី យើង វិញ យើងដឹងហើយថា ហេនរី យើង ជាសហព្រះរាជអាជ្ញាមួយដ៏ល្បីមួយនៅនូរឹមប៊ឺក ហើយគាត់បានសរសេរលិខិតមកកាន់មេធាវីការពារក្តី ដែលមេធាវីការពារក្តីស្នើសុំអាន តែត្រូវបានបដិសេធចោល ។ ហើយមានការស្នើសុំបញ្ចូលទៅក្នុងសំណុំរឿងចំពោះលិខិតនោះ ដោយសារតែលិខិតនោះបានបង្ហាញអំពីការយល់ឃើញរបស់សហព្រះរាជអាជ្ញាជាន់ខ្ពស់មួយរូប។ ប៉ុន្តែសហព្រះរាជអាជ្ញាបានដាក់ចូលទៅលើមួយទំព័រតែប៉ុណ្ណោះនៃចម្លើយរបស់គាត់នៅក្នុងសៀវភៅ ។ ហើយខ្ញុំដឹងថា ទំព័រមួយ ឬក៏ពីរទំព័រនោះ គឺវាទាក់ទងទៅនឹង អាល់ប៊ឺត ស្ពៀ ។ ដូច្នេះ គឺខ្ញុំយើងខ្ញុំដឹងហើយថា សៀវភៅនោះមានតែភាសាអង់គ្លេសតែប៉ុណ្ណោះ ។ ប៉ុន្តែ ខ្ញុំប្រហែលជាយល់ខុស ប្រហែលជាអាចមានជាភាសាបារាំងផងដែរ ។ ដូច្នេះ ហើយខ្ញុំសូមស្នើសុំទទួលយកតែពីរទំព័រ ឬក៏មួយទំព័រនោះបានហើយ ។

ហើយបន្ថែមទៅលើចំណុចហ្នឹង ទាក់ទងទៅនឹងលិខិតទៅលើ អាល់ប៊ឺត ស្ពៀ សូមឲ្យអង្គជំនុំជម្រះបង្គាប់ទៅដល់មេធាវីការពារក្តីដាក់លិខិតនោះ ចំពោះ ហេនរី យើង ដើម្បីឲ្យ ហេនរី យើង គាត់ធ្វើការឆ្លើយតប ។ ប៉ុន្តែយើងអាចមានតែចម្លើយរបស់គាត់តែប៉ុណ្ណោះ ដែលមាននៅក្នុងសវនាការរបស់យើង ប៉ុន្តែយើងមិនបានអានទៅលើចម្លើយរបស់លោក ហេនរី យើង នោះ ហើយចំពោះប្រតិចារឹក ខ្សែវីដេអូរឿងក្តី *អូប្រ៊ែណូរិច* វាអាចមេធាវីការពារក្តីវាជាប់ពាក់ព័ន្ធទៅនឹងគាត់ ។ ប៉ុន្តែ យើងខ្ញុំសូមលើកឡើងថា វាជាឯកសារយោងផ្លូវច្បាប់តែប៉ុណ្ណោះ វាមិនមែនជាភស្តុតាង ហើយមិនមែនជាចម្លើយរបស់អ្នកជំនាញនោះទេ ។ ហើយប្រសិនបើអង្គជំនុំជម្រះយោងទៅលើឯកសារសំអាងផ្លូវច្បាប់ទាំងអស់ ដែលបានដាក់ជូននោះ យើងឃើញថាមានរាប់ពាន់ទំព័រ ។ ដូច្នេះ ហើយប្រសិនបើមេធាវី-- បើសិនអង្គជំនុំជម្រះអនុញ្ញាតឲ្យមេធាវីការពារក្តីយោងទៅលើមូលដ្ឋានសំអាងផ្លូវច្បាប់នោះ គឺយើងអាចអនុញ្ញាតទៅ

បាន ប៉ុន្តែមិនមែនជាការដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះទេ ។ ហើយចំពោះសៀវភៅរបស់ *ទូទូ* វាទាក់ទងទៅនឹងការផ្សះផ្សាជាតិនៅអាហ្វ្រិកខាងត្បូង ។ សហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិ គឺយើងខ្ញុំធ្វើសម្បទាន ដូច្នេះ ហើយយើងខ្ញុំមិនមានបញ្ហាទេ ។

[១០:១៣:២១]

នៅចំណុចចុងក្រោយ ទាក់ទងទៅនឹងចម្លើយរបស់ ជុំ ម៉ី មេធាវីការពារក្ដីគាត់បានពន្យល់យ៉ាងច្រើន ថាតើការងារនោះធ្វើឡើយដោយសហចៅក្រមស៊ើបអង្កេតយ៉ាងម៉េច? ដូច្នេះហើយយើងគួរតែរៀបចំឱ្យបានត្រឹមត្រូវ ដាក់ជូនឱ្យបានមុនពេលវេលា ។ ប៉ុន្តែ ការកំណត់ត្រាចម្លើយដែលធ្វើឡើងដោយអ្នកកាសែត ប៉ារីស មេច (Paris Match) ខ្ញុំគិតថា គាត់មិនមែនជាអ្នកសរសេរក្នុងទស្សនាវដ្ដីវិជ្ជាជីវៈមួយនោះទេ ហើយយើងឃើញថា នៅថ្ងៃ២៦ ខែវិច្ឆិកា ឆ្នាំ២០០៨ វាដប់ខែជាងហើយ ហើយគាត់ ជុំ ម៉ី ជាដើមបណ្ដឹងរដ្ឋប្បវេណី ។ ហើយយើងដឹងហើយថា ចម្លើយនោះ គឺគ្រាន់តែជាអត្ថបទសារ-ព័ត៌មានដែលគាត់ជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ អាចប្រាប់និងមិនប្រាប់ទៅដល់អ្នកកាសែត ហើយវាមិនជាប្រយោជន៍ទៅដល់ការសរសេរសាលក្រមនោះទេ។ ដូច្នេះ ទោះបីជាមេធាវីការពារក្ដីសរសេរនៅក្នុងសន្និដ្ឋានបញ្ចប់ក៏ដោយ ប៉ុន្តែយើងខ្ញុំស្នើសុំឱ្យបដិសេធថា វាមិនមែនដាក់ចូលនៅក្នុងសំណុំរឿងនៅចំពោះមុខអង្គសវនាការរបស់យើងនោះទេ ។ សូមអរគុណ នេះជាអ្វីដែលខ្ញុំចង់លើកឡើង ។

**ប្រធានអង្គជំនុំ៖**

ខាងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តើមានអ្វីធ្វើការកត់សម្គាល់ ឬក៏សង្កេតទៅលើការស្នើសុំរបស់មេធាវីការពារក្ដីដែរឬទេ?

[១០:១៥:០៤]

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំក៏សូមគោរពលោក លោកស្រីចៅក្រមនៅក្នុងអង្គជំនុំជម្រះជាទីគោរព ។ ខ្ញុំបាទមេធាវី ហុង គីមសួន ជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងក្រុមទីពីរផង និងក្រុមទីបួនផង សូមជូនការសង្កេតទៅជាមួយនឹងលោកមេធាវីការពារដូចតទៅនេះ៖

ទាក់ទងជាមួយនឹងការលើកឡើងរបស់លោកសហព្រះរាជអាជ្ញាបរទេសអម្បាញ់មិញនេះ ខ្ញុំបាទក៏យល់ស្របជាមួយនឹងការលើកឡើងរបស់លោកផងដែរ ។ ដោយសារសៀវភៅដែលលោកមេធាវីការពារលើកឡើងនោះ មានសៀវភៅជាច្រើនដែលមានតែជាភាសាបរទេស ដែលខ្ញុំបាទជាមេធាវីជាតិ

មិនអាចយល់អំពីអត្ថន័យនៃភាសាបរទេសបាននោះ ។ នេះទីមួយ ។

ទីពីរទៀត និយាយឲ្យចំចំពោះកូនក្តីរបស់ខ្ញុំបាទ ឬក៏ជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ ម៉ី ។ កាលពីចាប់ផ្តើមសវនាការអង្គសេចក្តីដំបូង យើងក៏បានជជែកគ្នាជាច្រើនទាក់ទងជាមួយនឹងការព្រមព្រៀងអំពីអង្គហេតុ ។ ខ្ញុំនៅចាំបានថា បើមិនច្រឡំទេ លោកមេធាវីការពារបានជំទាស់យ៉ាងខ្លាំងក្លាចំពោះការសម្ភាសន៍ ឬការធ្វើកំណត់ហេតុរវាងលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាមួយនិងអ្នកសារព័ត៌មាន ឬខាង*យូអ៊ិន* ដែលធ្វើសម្ភាសន៍ជាមួយលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅខេត្តបាត់ដំបងមុនពេលដែលត្រូវបានឃាត់ខ្លួនគាត់នោះ ។ ហើយអង្គសវនាការ ជាពិសេសលោកប្រធាន និងអង្គជំនុំជម្រះបានទទួលយកបដិសេធនោះមិនអាចយកមកប្រើប្រាស់ជាផ្លូវការបានទេ ។

[១០:១៦:៤៥]

ហើយក្រោយមកទៀត ទាក់ទងជាមួយនឹងឯកសារអ្នកជំនាញការវៀតណាម ថតរូបជាវីដេអូផង និងមានរូបភាពផង ក៏ខាងមេធាវីការពារក្តីបានជំទាស់ដាច់អហង្ការដូចគ្នា រហូតមកទល់ពេលនេះលោកចៅក្រម និងលោកប្រធានបានទទួលយកសំណើរបស់លោកមេធាវីការពារមិនទទួលយកមកបង្ហាញ ។ ខ្ញុំបានសូមលើកអំពីឯកសារចុងក្រោយដែលលោកមេធាវីការពារយកមកស៊ុំលើជាសំអាងដែលនិយាយអំពីសេចក្តីសម្ភាសន៍របស់លោក ជុំ ម៉ី ជាមួយនិង ប៉ារីស មេច កាលពីថ្ងៃទី២០ ដល់ថ្ងៃ២៦ វិច្ឆិកា ឆ្នាំ២០០៨ នេះ ។

ខ្ញុំបាទនៅមានចម្ងល់ថា កាលពីថ្ងៃទី៣០ ខែ៦ ឆ្នាំ២០០៩ លោក ជុំ ម៉ី ដែលជាជនរងគ្រោះសេសសល់ជីវិតពីគុកទួលស្លែង ឬហៅមន្ទីរស-២១ ជំនាន់នោះ គាត់ជាដើមបណ្តឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះបានឡើងមកធ្វើសក្ខីកម្មនៅទីនេះអស់រយៈពេលពេញមួយថ្ងៃ ហើយដែលបានអនុញ្ញាតដោយលោកប្រធានឲ្យភាគីទាំងឡាយ មានភាគីលោកព្រះរាជអាជ្ញា ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងភាគីរបស់ជនជាប់ចោទផងដែរបានសាកសួរទៅលើគាត់ ។ ខ្ញុំបាទសួរថា ហេតុអ្វីពេលវេលាបើយើងប្រៀបធៀបពីថ្ងៃទី២០ ទៅដល់ ២៦ ខែវិច្ឆិកា ២០០៨ មកទល់ជាមួយនឹងថ្ងៃទី៣០ ខែ៦ ឆ្នាំ២០០៩ គឺឱកាសដែលលោក ជុំ ម៉ី បានមកធ្វើសក្ខីកម្មកន្លែងនេះ លោកមេធាវីការពារមិនយកសេចក្តីដែលគាត់បានថតចម្លង ឬក៏យកបានពីអ្នកកាសែតនេះយកមកសួរដេញដោល ដើម្បីឲ្យភាគីមានឱកាសសួរដេញដោលផង ។ នេះជាការយកចំណេញមួយទៅលើខាងកូនក្តី ឬក៏ខាងភាគីខាងយើងខ្ញុំជាដើមបណ្តឹងរដ្ឋប្បវេណីពិតប្រាកដណាស់ ។ ដូច្នេះ ហើយដើម្បីភាពសមរម្យ ឬក៏សមអាចទទួលយកបាន ខ្ញុំបាទមិន

ប្រើថា បើយុត្តិធម៌នោះទេ អាចទទួលយកបានខ្ញុំបាទសូមបដិសេធចោលទាំងស្រុងនូវការសុំបញ្ចូលឯកសារនេះធ្វើជាភស្តុតាងនៅក្នុងអង្គជំនុំជម្រះនៅពេលនេះ ។ ហេតុនេះ សូមលោកប្រធានមេត្តាបដិសេធចោលនូវការស្នើសុំរបស់មេធាវីការពារ ។ សូមអរគុណបាទ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី អាឡាំង វ៉ែនណឺ ។

[១០:១៩:១៣]

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ក្រុមទីមួយគាំទ្រនូវអ្វីដែលបានលើកឡើងទាក់ទងទៅនឹងករណី ជុំ ម៉ី ហើយប្រសិនបើឯកសារនេះត្រូវបានទទួលយកថាជាភស្តុតាងនោះ ដូច្នេះយើងគួរតែកោះហៅ ជុំ ម៉ី ដោយសារតែវាជាឯកសារបឋម ។ ដូច្នេះហើយ ជុំ ម៉ី គួរតែផ្តល់ឱកាសឲ្យការបង្ហាញនិងឆ្លើយនូវអ្វីដែលគាត់បាន ឬក៏មិនបាននិយាយទៅ ប៉ារីស មេច ហើយប្រសិនបើយើងទទួលយកឯកសារនេះ យើងគួរតែកោះហៅ ជុំ ម៉ី ហើយឲ្យ ជុំ ម៉ី គាត់ជម្រាបយើងថា តើគាត់បាននិយាយ ឬក៏មិនបាននិយាយនូវអ្វីដែលបានកត់ត្រាដោយអ្នកកាសែត? យើងដឹងហើយថា វាជាការប្រុងប្រយ័ត្នមួយដែលថា យើងត្រូវដឹងនូវអ្វីដែលគាត់បានលើកឡើង ។

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព ។ ខ្ញុំសូមផ្តល់ជាយោបល់។ ប្រសិនបើខ្ញុំចាំមិនខុសទេនោះ នៅពេលដែលយើងនិយាយអំពីសៀវភៅ *ដេសមិន ទូទូ* មេធាវីការពារក្តីត្រូវបានចោទសំណួរឲ្យបញ្ជាក់អំពីផ្នែកណាមួយដែលមេធាវីការពារក្តីចង់យកមកធ្វើជាមូលដ្ឋាន ហើយចំពោះមេធាវី រូ គាត់យល់ព្រមក្នុងការបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធដែលគាត់យកមកធ្វើជាមូលដ្ឋាន។ ហើយប្រសិនបើអ៊ីចឹងមែននោះ យើងខ្ញុំរីករាយណាស់ដែលថា ធ្វើយ៉ាងណាឲ្យមេធាវីការពារក្តីអាចបញ្ជាក់ទៅលើផ្នែកដែលពាក់ព័ន្ធគាត់ចង់យកមកធ្វើជាមូលដ្ឋាន ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ហ្វ្រង់ស្វ័រ រូ អាចតបបានទៅនឹងសំណួររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីដែរឬទេ?

[១០:២១:៤៣]

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

លោកប្រធានជាទីគោរព! ខ្ញុំពិតជាបានសន្យាផ្តល់នូវការបកប្រែទៅលើអត្ថបទដែលខ្ញុំចង់យកមកធ្វើជាមូលដ្ឋាននៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់របស់ខ្ញុំ ។ ប៉ុន្តែ ដោយសារតែយើងមានរយៈពេលពីរខែក្នុងការរៀបចំទៅលើឯកសារនេះ ហើយលោកស្រីមេធាវីនឹងទទួលបាននូវឯកសារនោះមុនពេលដែលខ្ញុំធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់ ។

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

សូមអរគុណច្រើនលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រមមានអ្វីបញ្ជាក់លើបញ្ហាដែលលើកឡើងដោយមេធាវីការពារក្តីនេះដែរឬទេ? បើមិនមានទេគឺអង្គជំនុំជម្រះសូមបន្តទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅបីក្រុមទៀតក្រុមបី តើ--

អញ្ជើញលោក ហ្វ្រង់ស្វ័រ រ៉ូ អំមិញយើងគិតថា ចប់ហើយ ពីព្រោះយើងបានសួរបញ្ជាក់ហើយថាវាមានបញ្ហាអីទៀតអត់? ដូចអត់មានអ្នកឆ្លើយទេ អ៊ីចឹងបានយើងបន្តទៅកិច្ចនីតិវិធីបន្តបន្ទាប់ ។ ឥឡូវស្រាប់តែមកបកក្រោយវិញ ។

អញ្ជើញ ។ សូមលោកពិចារណាឡើងវិញអំពីពេលវេលា គួរតែត្រូវធ្វើយ៉ាងណាឲ្យបានច្បាស់លាស់តែម្តងទៅ ហើយប្រសិនបើធ្វើបញ្ជាក់សាឡើងវិញ គឺបញ្ជាក់អ្វីដែលថ្មី ដែលមានបញ្ហាបានហើយមិនអាចនឹងគប្បីនិយាយសាដើមដដែលៗឡើងវិញទេ ។ បើនិយាយដដែលហ្នឹងនិយាយដល់ពេលណាក៏មិនចប់ដែរ ហើយក៏មិនក្តាប់ព័ត៌មានដើម្បីចេញសេចក្តីសម្រេចមួយច្បាស់លាស់បានទេ ។ ប្រសិនបើកាលដែលលើកឡើងហ្នឹងមិនច្បាស់លាស់ ហើយមានភាពច្របូកច្របល់នោះ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

សូមអរគុណច្រើនលោកប្រធាន ។ ខ្ញុំគ្រាន់តែចង់ផ្តល់ឱកាសពីលោកប្រធានឆ្លើយតបទៅនឹងអ្វីដែលសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងអំពីពាក្យសុំដែលខ្ញុំបានដាក់ជូននេះ ។ សហព្រះរាជអាជ្ញា គាត់មានឱកាសនៅក្នុងការឆ្លើយតបទៅនឹងចម្លើយរបស់ខ្ញុំ ដែលខ្ញុំបានធ្វើចំពោះនឹងការដាក់ឯកសាររបស់គាត់ ។ ដូច្នេះហើយខ្ញុំសូមឆ្លើយតបទៅនឹងចំណុចហ្នឹង ទៅលើឯកសារ ដោយនិយាយដោយខ្លីៗ ដើម្បីបញ្ជាក់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមិនដឹងថាតើជាការនិយាយដោយតំណាង

ទៅលើ ជុំ ម៉ី ឬក៏យ៉ាងម៉េច? មេធាវីការពារក្ដីយើងពិចារណាឃើញថា វាមិនមានភាពសំខាន់វាមិនមានសារប្រយោជន៍ក្នុងការបង្ហាញទៅលើឯកសារនេះ មុនពេលដែលយើងបង្ហាញនូវខ្សែវីដេអូនោះទេ ដែលនៅពេលនោះវាមានការសម្ភាសន៍ជនជាប់ចោទទៅលើអត្តចរិតរបស់គាត់ ហើយប្រសិនបើយើងមិនទទួលយកឯកសារនោះទេ ខ្ញុំមិនមានបញ្ហានោះទេ គឺថាយើងអាចបញ្ចាំងតែខ្សែរូបភាពនោះបានហើយ។ ដូច្នេះ ហើយខ្ញុំមិនប្រើឯកសារនោះជាភស្តុតាងនោះទេ ខ្ញុំគ្រាន់តែយោងឯកសាររបស់ ជុំ ម៉ី ក្នុងពេលដែលខ្ញុំធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់តែប៉ុណ្ណោះ ។

[១០:២៦:០៧]

ដូច្នេះហើយយើងមិនមានហេតុផលដែលចាំបាច់កោះហៅ ជុំ ម៉ី នោះទេ ហើយឆ្លើយតបទៅចម្លើយសេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញា ជាពិសេសទាក់ទងទៅនឹងសៀវភៅ ហ្វីលីព សត ។

ខ្ញុំហាក់ដូចជាភ្ញាក់ផ្អើលណាស់ ដែលថា សហព្រះរាជអាជ្ញាជំទាស់ការដាក់ឯកសារសៀវភៅនៅចំពោះមុខតុលាការ ប្រសិនបើអ៊ីចឹងមែននោះ គឺថា ខ្ញុំនឹងប្រើប្រាប់សៀវភៅនោះដើម្បីសរសេរក្នុងសន្និដ្ឋានបញ្ចប់របស់ខ្ញុំ ។ ដូច្នេះហើយនៅពេលដែលខ្ញុំដាក់អ្វីដែលខ្ញុំចង់ដាក់សៀវភៅ គឺខ្ញុំគ្រាន់តែចង់ឲ្យលោកដឹងថា តើខ្ញុំនឹងយោងនៅចំណុចណាខ្លះ? ប្រសិនបើលោកមិនចង់ដឹងអត់បញ្ហាទេចំពោះខ្ញុំ ។ ហើយចំណុចដែលខ្ញុំធ្វើឡើងនេះ គ្រាន់តែចង់ឲ្យអង្គជំនុំជម្រះដឹងថា ឯកសារណាខ្លះដែលខ្ញុំសំអាងនៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់របស់ខ្ញុំ ហើយវាអាស្រ័យទៅលើអង្គជំនុំជម្រះដែលថា ឯកសារនេះបានដាក់នៅចំពោះសវនាការរបស់យើង ឬក៏វាបានសរសេរជាក់លាក់ទៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់របស់ខ្ញុំ ដើម្បីឲ្យអង្គជំនុំជម្រះបានយកទៅពិចារណា ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ម៉ោងត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយ ខ្វះម្ភៃនាទី សឹមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:២៨នាទី ដល់ម៉ោង១០:៥៤នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាកិច្ចបន្តនេះ អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីកតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ និងក្រុមបួនដើម្បីមានឱកាសក្នុងការសម្រេចបំណងរបស់ខ្លួននូវការស្នើសុំដាក់ឯកសារ ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ នូវឯកសារដែលសេសសល់ ដែលមិនទាន់បាន-- ខ្លួនយល់ឃើញថា មិនទាន់បានដេញដោលនៅក្នុងអំឡុងពេលដំណើរការសវនាការកន្លងមក ។ សូមអញ្ជើញ ។

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ខ្ញុំបាទសូមគោរពអង្គសវនាការជាទីគោរពម្តងទៀត ។ ជាដំបូងនេះខ្ញុំបាទសូមអនុញ្ញាតលោកប្រធានសូមបញ្ជាក់បន្តិចសិន ព្រោះមុននឹងសម្រាកអំមិញហ្នឹង បើសិនជាខ្ញុំបាទស្តាប់មិនច្បាស់ដោយសារការបកប្រែក៏មិនដឹង ត្រង់ថាលោកមេធាវីការពារ គាត់បានទទួលយកអំពីការជំទាស់ឯកសារសម្ភាសន៍លោក ជុំ ម៉ី ។ ប៉ុន្តែ បើជាខ្ញុំស្តាប់ទៅ ហាក់ដូចជាឮថា សូមឲ្យជំនួសការបញ្ចាំងវីដេអូវិញ ។

ខ្ញុំបាទសូមឲ្យបញ្ជាក់កន្លែងបន្តិច តើខ្ញុំបាទស្តាប់ច្រឡំ ឬក៏គាត់មានបំណងសូមឲ្យបញ្ចាំងជាវីដេអូទៅវិញ ។ កន្លែងហ្នឹងមួយបាទ ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ហ្វ្រង់ស្វ័រ រូ អាចបញ្ជាក់បញ្ហាចំណុចនេះបានទេ?

លោកយល់ទេ? យល់នូវសំណួររបស់លោក-- ចម្លល់របស់លោកមេធាវី ហុង គីមសួន ដែរទេ? សូមលោកបំភ្លឺលើចំណុចនេះឲ្យបានច្បាស់ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំបាននិយាយថា ពីម្សិលមិញល្ងាចហើយនិងព្រឹកនេះថា ពីម្សិលមិញនោះយើងបានបង្ហាញបញ្ចាំងវីដេអូ ដែលនិយាយពីការសម្តែងឡើងវិញនៃស-២១ ហើយខ្ញុំនិយាយថា នៅក្នុងវីដេអូនោះ យើងអាចឃើញលោក ជុំ ម៉ី បាននិយាយ ។ ហើយខ្ញុំក៏បាននិយាយដែរថា យើងមិនចង់ ចង់ស្នើ ឬក៏ចង់ដាក់នូវបទសម្ភាសន៍របស់លោក ជុំ ម៉ី មុនពេលការបង្ហាញ ឬក៏ការបញ្ចាំងវីដេអូនៃការសម្តែងឡើងវិញហ្នឹងមុនពេលដាក់ឯកសារ ។ ហើយនេះជាមូលហេតុដែលថាបទសម្ភាសន៍របស់លោក ជុំ ម៉ី ត្រូវបានដាក់តែម្សិលមិញនៅចុងបញ្ចប់ពេលល្ងាច ពីព្រោះវីដេអូនៃការសម្តែងឡើងវិញនោះត្រូវបានបញ្ចាំងមុន

គឺបញ្ជាំងពីព្រឹក ។

ដោយហេតុនោះហើយ ចៅក្រម ខាតរាយចំ បានបញ្ជាក់ដែរថា ថាវីដេអូនោះអាចនឹងយកមក បញ្ចាំងបាននៅពេលដែលយើងពិនិត្យសព្វគ្រប់ទៅលើអត្តចរិតរបស់ជនជាប់ចោទ ។ នេះហើយ យើង ច្បាស់លាស់ហើយនូវចំណុចនេះ ។

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ខ្ញុំបាទបានស្តាប់ច្បាស់ហើយបាទ ។ តទៅទៀតនេះ ខ្ញុំសូមជម្រាប លោកប្រធាន និងអង្គសវនាការអំពីការអនុញ្ញាតឲ្យខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ និងក្រុម បួនមានឱកាសចុងក្រោយក្នុងការបញ្ចេញ ឬបង្ហាញ បើសិនជាមានឯកសារថ្មី ។

ចំពោះខាងមេធាវីក្រុម ដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ និងបួននេះ ឯកសារថ្មីសុទ្ធសាធមិនមាន ទេ ប៉ុន្តែខ្ញុំបាទសូមជម្រាបជូនពីឯកសារ ដែលមាន ដែលខ្ញុំបាទបានដាក់ជូននៅក្នុងឱកាសក្នុងចន្លោះថ្ងៃ ទី២៧ ខែ៨ ឆ្នាំ២០០៩ រហូតមកទល់នឹងថ្ងៃទី១០ ខែ៩ ឆ្នាំ២០០៩ ។

[១០:៥៨:៤៣]

ក្នុងនេះខ្ញុំបាទសូមជម្រាបលោកប្រធានថា នៅក្នុងឱកាសចុងក្រោយ ឬក៏នៅពេលលោកប្រធាន សម្រេចប្រកាសជាសាលក្រមនោះ ខ្ញុំបាទសូមឲ្យលោកប្រធានមេត្តាលើកយក ឬក៏លោកប្រធានអាចសុំ ទៅតាមការសុំរបស់ខ្ញុំ សូមបញ្ចូលឯកសារដែលមានលេខ ERN ជាភាសាខ្មែរ 00369908 ទៅដល់ 00372191 និងជាភាសាអង់គ្លេសលេខ 00372188 ទៅដល់លេខ 00372191 ដែលនិយាយអំពី ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានលេខសម្គាល់ E2/32 ដែលទាក់ទិនជាមួយនឹងការ-- ត្រូវបានអ្នកយាមកងការពារឆ្នាំនៅមន្ទីរស-២១ ចាប់រំលោភសេពសន្ថវៈគាត់ទៅក្នុងការចេញសាលក្រម របស់អង្គជំនុំជម្រះសាលាដំបូងចុងក្រោយផង ។

ដូច្នេះខ្ញុំបាទ មានតែប៉ុណ្ណេះទេ សូមលោកប្រធានជ្រាបបាទ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តី តើមានមតិយោបល់អ្វីទេអំពីការស្នើសុំដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ និងក្រុមបួន ដែលបានលើកឡើងអម្បាញ់មិញនេះ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ យើងកំពុងតែពិនិត្យទៅលើឯកសារដែលលើកឡើងដោយមេធាវី

ការពារក្តី ។ តើនោះជាលិខិតផានាអះអាង ឬក៏យ៉ាងម៉េច? តើខ្ញុំបញ្ជាក់នេះត្រឹមត្រូវដែរឬទេ? ដែលលោកចង់ដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះ ។ តើវាជាលិខិតធានាអះអាងឬក៏មិនមែន?

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ហុង គឹមសួន សូមបញ្ជាក់អំពីអត្តសញ្ញាណឯកសារ ដែលជាឈ្មោះ ។ ចំណងជើងឯកសារនេះឈ្មោះអី?

**លោក ហុង គឹមសួន៖**

សូមជម្រាបលោកប្រធាន គឺចំណងជើង “ការសុំដាក់សេចក្តីថ្លែងការណ៍បន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណីលេខ E32 ទៅក្នុងសំណុំរឿង០០១ ចុះថ្ងៃទី១៨ ខែ៧ ឆ្នាំ២០០៧ អ.វ.ត.ក/អ.ជ.ស.ដ” ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ការ សាវុត្ថ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណនិងសូមគោរពលោកប្រធាន ។ ខ្ញុំយល់ថា ពាក្យបណ្តឹងដែលដាក់បន្ថែមនេះ ពាក្យដាក់បន្ថែមនេះ វាហាក់ដូចជាវា អង្គហេតុថ្មី ពីព្រោះក្នុងចៅក្រមស៊ើបអង្កេតដែលបញ្ជូនរឿងមកជម្រះអត់មានបញ្ហានេះទេ ។ ដូច្នេះ ខ្ញុំជាមេធាវីការពារជនជាប់ចោទ សូមបញ្ជាក់ថា បើសិនជាវាមានអ្នកយាមទៅរំលោភពេទ្យដោយប្រធានអង្គភាពអត់បានដឹង ដូច្នេះវាមិនមែនជាកំហុសរបស់ប្រធានអង្គភាពទេ ពីព្រោះនៅក្នុងសម័យ ប៉ុល ពត រឿងសីលធម៌នេះ អត់មានអ្នកណាហ៊ានប្រកែកបានទេ តែមានភស្តុតាងជាក់ស្តែង គឺដាច់កអីចឹងតែម្តង ។

ដូច្នេះ រឿងនេះការស៊ើបអង្កេតអត់មានទេ ខ្ញុំអត់បានឮសួរ អត់មាននេះអីចឹងទេ ។ វាមានតែអ្នកសួរចម្លើយនោះ ដែលបានរំលោភទៅជនរងគ្រោះ អាហ្នឹងវាមាន ហើយកាលនៅស៊ើបអង្កេតមិនមានរឿង ដែលថាអ្នកយាមទៅរំលោភលើពេទ្យ លើអី គឺអត់មានទេ ។ ដូច្នេះខ្ញុំបាទ សូមបដិសេធចោលមិនទទួលស្គាល់នូវអង្គហេតុថ្មី ដែលទើបនឹងដាក់នេះទេ ។ សូមអរគុណ ។

[១១:០៤:១០]

**ប្រធានអង្គជំនុំ៖**

ជាបន្តសូមប្រគល់វេទិកាទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ដើម្បីមានឱកាសក្នុងការស្នើសុំដាក់ឯកសារដែលខ្លួនមានបំណងក្នុងការដាក់ឯកសារ ដើម្បីលើកមកពិភាក្សាដេញដោល ចាត់

ទុកជាការលើកពិភាក្សាដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ។

**លោក គីម ម៉េងឃី៖**

សូមអរគុណលោកប្រធាន ។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! ខ្ញុំបាទតំណាងឲ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី សូមពាក់ព័ន្ធទៅនឹងការដាក់ឯកសារថ្មី គឺយើងខ្ញុំមិនមានឯកសារសម្រាប់ដាក់ថ្មីទៀតទេ។ ក៏ប៉ុន្តែ យើងខ្ញុំបានដាក់ឯកសារនៅក្នុងសំណុំរឿងពាក់ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី គ្រប់គ្រាន់រួចរាល់តាមសេចក្ដីបង្គាប់របស់អង្គជំនុំជម្រះហើយ ដូចជាមាននៅក្នុងឯកសារ E139 ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ និងឧបសម្ព័ន្ធ E161 ចុះថ្ងៃទី២៨ សីហា ឆ្នាំ២០០៩ និងឧបសម្ព័ន្ធ ហើយនិងចុងក្រោយ គឺ E164 ។ ដូច្នេះ ចំពោះឯកសារថ្មី យើងខ្ញុំមិនមានអ្វីដាក់ទៀតទេ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបញ្ជាក់ម្ដងទៀតមើល៍ ចង់ៗថាម៉េចឥឡូវហ្នឹង? លើឯកសារដែលលោកបង្ហាញអម្បាញ់មិញនេះ?

ឥឡូវនេះ អង្គជំនុំជម្រះទទួលការស្នើសុំដាក់ឯកសារនៅចំពោះអង្គជំនុំជម្រះ ដោយចាត់ទុកថាបង្ហាញនូវអត្តសញ្ញាណឯកសារដែលមាននៅក្នុងសំណុំរឿង ដែលមិនបានដកយកមកពិភាក្សាដេញដោលនៅក្នុងអំឡុងពេលនៃដំណើរការសវនាការចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ មករហូតដល់ពេលនេះ ដើម្បីបំពេញកិច្ចនៅក្នុងដំណើរការនីតិវិធីថា ភស្តុតាងទាំងអស់ត្រូវតែលើកយកមកពិភាក្សាដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ទើបកំណត់ថាជាភស្តុតាងនៅក្នុងសំណុំរឿង ហើយជាមូលដ្ឋាននាំឲ្យអង្គជំនុំជម្រះហ្នឹងយកទៅថ្លឹងថ្លែង យកទៅវិភាគពិចារណា វាយតម្លៃ ដើម្បីរៀបចំសាលក្រម សេចក្ដីសម្រេចរបស់ខ្លួន ។ ហើយដោយសារហេតុផលសំណុំរឿងវាធំធេង ហើយឯកសារច្រើន យើងក្នុងកិច្ចពិភាក្សាដេញដោលកន្លងមក បារម្ភក្រែងលោឯកសារចាំបាច់មួយចំនួនហ្នឹងគឺមិនអស់ ។ យល់ឃើញថាមិនទាន់បានពេញលេញ សុំឲ្យអាចអនុញ្ញាតឲ្យភាគីលើកនូវឯកសារទាំងនោះមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយចាត់ទុកថា ឯកសារនោះត្រូវបានពិភាក្សាដេញដោល បើមិនបានមានការជំទាស់ពីភាគីណាមួយច្បាស់លាស់ទេ លើកលែងតែមានការជំទាស់នោះអង្គជំនុំជម្រះនឹងសម្រេចនៅក្រោយ ។

លោកអាចបញ្ជាក់បញ្ហានេះបានទេ ឬក៏អត់មានបញ្ហាអីទេ? គ្រាន់តែឯកសារចាស់ គ្រាន់តែជាការបង្ហាញប៉ុណ្ណោះ មិនមែនជាការស្នើសុំដាក់ទេ?

**លោក គឹម ម៉េងឃី៖**

បាទ, សូមបញ្ជាក់លោកប្រធាន ជាការពិតណាស់ គឺឯកសារដែលយើងបានដាក់នោះ យើងចង់បានបង្ហាញថា បានដាក់រួចហើយទៅនៅចំពោះសម្រាប់ការដេញដោលទៅលើពាក្យសុំតាំងខ្លួន ។ ដូច្នេះមិនមែននៅក្នុងគោលបំណងដេញដោលនៅពេលក្រោយ ឬក៏បន្ថែមអ្វីទៀតទេ ។ នេះគឺជាការបញ្ជាក់ ។ សូមអរគុណ ។

[១១:០៨:១០]

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តី តើមានអ្វីកត់សម្គាល់អំពីការលើកឡើងរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីនេះទេ?

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

ខ្ញុំមានចំណុចពីរចង់ធ្វើការសង្កេត យើងខ្ញុំបានទទួលពីក្រុមដើមបណ្តឹងរដ្ឋប្បវេណីនូវឯកសារបន្ថែម ដែលអង្គជំនុំជម្រះបានស្នើសុំ ។ ឯកសារទាំងអស់នោះ គឺទាក់ទងទៅនឹង D24 ដែលមេធាវីការពារក្តីបានតវ៉ា ។ ជំហររបស់មេធាវីការពារក្តី ទាក់ទងទៅនឹងឯកសារបន្ថែមនេះ យើងចង់ផ្អែកការសម្រេចជូនអង្គជំនុំជម្រះ បានន័យថា អង្គជំនុំជម្រះជាអ្នកសម្រេចក្នុងការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី E2/64 ដែល ឌុច បានទទួលស្គាល់យ៉ាងច្បាស់ថា បុគ្គលនោះបានជាប់នៅមន្ទីរស-២១ បន្ទាប់ពីការពិនិត្យទៅលើឯកសារទាំងឡាយដែលបានផ្តល់ជូនជនជាប់ចោទ ។

[១១:១០:០០]

ក្រៅពីនេះ ដើម្បីយើងអាចបញ្ចប់ទៅលើបញ្ហានៃការដាក់ឯកសារថ្មី ដែលបានដាក់ជូនកាលពីម្សិលមិញនោះ ដែលដាក់ដោយមេធាវីអាឡាំង វ៉ែនណឺ និង ទី ស្រ៊ុនណា គឺឯកសារនោះ គឺបានលើកឡើងថា ទើបតែរកបានថ្មីៗនៅមន្ទីរស-២១ ។ ជនជាប់ចោទ គឺជនជាប់ចោទអាចស្នើសុំឲ្យផ្តល់ជំហរទៅលើឯកសារ និងខ្លឹមសារសំខាន់នៃឯកសារនោះ បន្ទាប់មកមេធាវីការពារក្តីនឹងផ្តល់យោបល់ទៅលើឯកសារខ្លឹមសារនុ៎ង ហើយបន្ទាប់មកគឺអង្គជំនុំជម្រះអាចធ្វើការដោះស្រាយហើយនិងធ្វើការសម្រេចទៅលើឯកសារដែលបានលើកឡើងកាលពីម្សិលមិញនោះ នៅព្រឹកនេះតែម្តង ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ។

**លោក អាឡាំង វែនណើ៖**

លោកប្រធានជាទីគោរព! យើងខ្ញុំរីករាយណាស់ដែលមេធាវីបានលើកឡើងទៅលើចំណុចនេះ ហើយយើងមិនមានការផ្លាស់ប្តូរទេ ដែលថាយើងនឹងដាក់ជូនពាក្យសុំទៅលើឯកសារទាំងអស់នេះទៅលើការបកប្រែ ។ ដូច្នេះហើយយើងគិតថា ខ្ញុំ នៅពេលដែលខ្ញុំបានបញ្ជូនឯកសារបកប្រែហើយ វាជាការល្អដែលមេធាវីអាចពិនិត្យទៅលើឯកសារនោះបាន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅ? ជនជាប់ចោទតើមានការកត់សម្គាល់យ៉ាងម៉េចទៅ? ការសង្កេតយ៉ាងម៉េចទៅលើការស្នើសុំដាក់ឯកសារថ្មី របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយនេះ ចំនួនដប់ប្រាំបីឯកសារ?

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ឯកសារទាំងដប់ប្រាំបីនេះ ខ្ញុំបាទពិនិត្យច្បាស់លាស់របស់ខ្ញុំ តាមទម្រង់តាមមានលេខ TSL ហើយអក្សរ គឺអក្សរមិត្ត ហ៊ា និងស៊ីញ៉េមិត្ត ហ៊ា ។ ដូច្នេះ ខ្ញុំទទួលស្គាល់ថាឯកសារនេះ វាជាឯកសាររបស់ស-២១ មែន ។ ឯចំណែករឿងខាងផ្លូវច្បាប់ ខ្ញុំសូមទុកជូនលោកមេធាវីរបស់ខ្ញុំលោកបញ្ជាក់ជូនអង្គជំនុំជម្រះ ។ សូមបញ្ចប់ប៉ុណ្ណេះដោយគោរព ។

[១១:១២:៥៥]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅលោកមេធាវីការពារ?

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។ រឿងនេះខ្ញុំនៅតែរក្សាគំនិតរបស់ខ្ញុំកាលពីម្សិលមិញនៅដដែល គឺខ្ញុំមិនអនុញ្ញាតឲ្យដាក់ចូលទៅក្នុងសំណុំរឿងទៀតទេ មិន-- គឺថាសុំទាត់ចោល ។ ហេតុអីបានជាខ្ញុំទាត់ចោល? ពីព្រោះគ្រប់ឯកសារទាំងអស់ ដែលពាក់ព័ន្ធនឹងស-២១ ត្រូវតែបានយកមកសួរដេញដោលនៅតាំងពីចៅក្រមស៊ើបអង្កេត ហើយរឿងនេះទើបតែយកឯកសារថ្មីមក គឺអត់ទាន់បានសួរដេញដោល អត់ទាន់បានអីទាំងអស់ ។ ដូច្នេះ យើងខ្ញុំទទួលយកមិនបានទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីអន្តរជាតិ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ដូច្នេះបញ្ហានេះបញ្ជាក់ច្បាស់លាស់ហើយ ឯកសារទាំងអស់នោះពិតជាចេញមកពីមន្ទីរស-២១ មែន ពិតជាឯកសារនុំងមែន។ ប៉ុន្តែ យើងខ្ញុំសូមបញ្ជាក់ផ្ទុយពីនេះ ថាតាមផ្លូវច្បាប់ គឺយើងមិនអាចយកឯកសារប្រភេទនេះ យកមកបង្ហាញដេញដោល ហើយដាក់នៅចំពោះមុខចុងក្រោយនៅពេលនេះទេ ។ ដូច្នេះហើយខ្ញុំមានបទពិសោធន៍តិចណាស់តែសាមប្រាំពីរឆ្នាំតែប៉ុណ្ណោះ ។ ដូច្នេះខ្ញុំសូមបញ្ជាក់ថា រាល់ពេលដែលខ្ញុំដាក់ ឃើញថាឯកសារដែលដាក់នៅពេលចុងក្រោយបែបនេះ គឺយើងមិនអាចអនុវត្តបាននោះទេ ។ បាទ, ជាការពិតឯកសារនោះចេញមកពីស-២១ មែន ប៉ុន្តែមិនអាចដាក់ជូនអង្គសវនាការនៅថ្ងៃនេះបានទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា អាចមានបញ្ហាថ្មីទេ? អនុញ្ញាតឲ្យនិយាយរឿងថ្មី បើរឿងចាស់ដូចជាចប់ហើយ ហើយរឿងថាតែមានការប្រែប្រួល ដល់ពេលមកទៅគឺរឿងដដែលអត់មានអីប្រែប្រួលផង ហើយអីចឹងមិនបាច់ទៅលើកយកមកបញ្ជាក់ធ្វើអ្វី? ដូចជាអត់មានប្រយោជន៍អីសោះ! ដូច្នេះគឺអង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីដែលមានបញ្ហាថ្មីផ្សេងទៀត អាចលើកចុងក្រោយបានមុននឹងអង្គជំនុំជម្រះប្រកាសផ្អាកដំណើរការសវនាការ ។ បើរឿងដែលមានរួចហើយ គឺមិនអនុញ្ញាតឲ្យនិយាយអ្វីទៀតទេ ។

[១១:១៥:៥៨]

**លោក អានីស អះមេដ៖**

ខ្ញុំទទួលយកនូវការណែនាំរបស់អង្គជំនុំជម្រះ គឺជាចំណុចថ្មី ទាក់ទងទៅនឹងឯកសារនេះកាលពីម្សិលមិញយើងខ្ញុំមិនបានប្រកាន់ជំហរណាមួយនោះទេ ដោយសារតែមិនមានការបញ្ជាក់អំពីយថាភាព ហើយនៅពេលនេះយើងឃើញថា ជនជាប់ចោទគាត់បានទទួលស្គាល់នូវឯកសារនោះហើយ ដូច្នេះយើងគួរតែទទួលយកនូវឯកសារនោះ ដាក់នៅចំពោះមុខអង្គជំនុំជម្រះរបស់យើង ។

**លោក អាឡាំង វែនណឺ៖**

លោកប្រធានជាទីគោរព! សូមអនុញ្ញាតឲ្យខ្ញុំឆ្លើយតប ឬក៏និយាយសាថ្មីនូវអ្វីដែលខ្ញុំបានលើកឡើង ហើយយើងខ្ញុំបាននិយាយហើយ ដូចដែលខ្ញុំបានលើកឡើងកាលពីម្សិលមិញ ។ ដូច្នេះ ខ្ញុំមិនមានអ្វីបញ្ជាក់បន្ថែមទៅលើចំណុចទាំងអស់នេះទៀតទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

តើអស់លោក លោកស្រីចៅក្រមមានបញ្ហាអីត្រូវនិយាយទៀតទេ? មានចំណាប់អារម្មណ៍អ្វីទៀតទេលោក ហ្សង់ម៉ាក? បើមិនមានបញ្ហាអីទេ? អញ្ជើញលោក អាឡាំង វ៉ែនណឺ អំមិញខ្ញុំបានប្រាប់ហើយ ថាបើមានបញ្ហាអីគឺអាចលើកឡើងបាន ។ នេះជាស្ថានភាពនៃឱកាសចុងក្រោយនៃដំណើរការសវនាការនៅសម្រាប់ថ្ងៃនេះ ដើម្បីបញ្ជាក់ គ្រាន់តែរឿងអ្វីដែលបានជជែករួចហើយ ដែលនៅតែមានបញ្ហានេះ អង្គជំនុំជម្រះបានទទួលព័ត៌មានសព្វគ្រប់ល្មមនឹងអាចចេញសេចក្តីសម្រេចបានហើយ។ អ៊ីចឹងមិនចាំបាច់បញ្ជាក់ថែមទៀតទេ នូវអ្វីដែលបានជជែកពិភាក្សាគ្នាកន្លងមកនេះ ។

សូមនិយាយរឿងថ្មី ប្រសិនបើមាន ។

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំសូមនិយាយជាភាសាអង់គ្លេស ដោយសារតែខ្ញុំមានសំណើដែលខ្ញុំចង់និយាយជាភាសាអង់គ្លេសសំណើខ្លីតែប៉ុណ្ណោះ ហើយខ្ញុំចំណាយពេលតែមួយនាទី ។

នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ គឺបួនខែកន្លះហើយ ក្រុមដើមបណ្តឹងមេធាវីរបស់យើងខ្ញុំក្រុមទីមួយ គឺបានដាក់សំណើ គឺសំណើសុំឲ្យអង្គជំនុំជម្រះជួយសម្រួលចេញរបាយការណ៍ *អូអាយអូអេស* (OIOS) ជូនភាគី ។ ហើយនៅក្នុងសំណើនោះ អ្វីដែលយើងស្នើសុំពីអង្គជំនុំជម្រះនោះ គឺស្នើសុំអង្គជំនុំជម្រះឲ្យភាគីដាក់សេចក្តីសន្និដ្ឋានទាក់ទងទៅនឹងខ្លឹមសាររបាយការណ៍ *អូអាយអូអេស* នៅក្នុងរយៈពេល២១ថ្ងៃ បន្ទាប់ពីយើងទទួលបានទៅលើរបាយការណ៍នេះ ។

[១១:១៨:៥២]

ដូច្នេះហើយ គឺអង្គជំនុំជម្រះធ្វើសំណើសុំទៅកាន់ *អូអាយអូអេស* ហើយយើងបានពិនិត្យមើលនៅព្រឹកមិញនេះ ហើយមិនមានការចេញសេចក្តីសម្រេច ទៅលើសំណើរបស់យើងខ្ញុំនោះទេ ។ ដូច្នេះហើយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត គឺចូលរួមស្នើសុំជាមួយខ្ញុំដែរ ។ ដូច្នេះ វាជាសំណើរួមតែម្តង ។ ខ្ញុំស្នើសុំអង្គជំនុំជម្រះទៅលើបញ្ហានេះ ដោយសារតែយើងដឹងថា យើងនឹងបញ្ចប់រឿងក្តីរបស់យើងនៅពេលឆាប់ៗនេះ ។ ហើយយើងខ្ញុំសូមឲ្យអង្គជំនុំជម្រះបញ្ជាក់ទៅមើល ថាតើនៅពេលណាដែលអង្គជំនុំជម្រះអាចចេញសេចក្តីសម្រេចទៅលើសំណើរួមរបស់យើងខ្ញុំនេះ ដើម្បីឲ្យយើងខ្ញុំអាចត្រៀមខ្លួនរៀបចំទៅលើបញ្ហាទាំងអស់នេះ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។

អញ្ជើញលោកហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

មិនត្រឹមតែលើកបញ្ហានេះទេ មុនពេលដែលលោកប្រធានធ្វើការផ្អាកសវនាការរបស់យើង យើងខ្ញុំសូមអរគុណផងដែរ ប្រសិនបើអង្គជំនុំជម្រះអាចជម្រាបជូនយើងខ្ញុំ ថាតើរយៈពេលកំណត់ប៉ុន្មានដែលភាគីទទួលបាននៅពេលដែលយើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់? វាមានសារប្រយោជន៍ ប្រសិនបើអង្គជំនុំជម្រះអាចជម្រាបទៅលើរយៈពេលកំណត់ផ្តល់ជូនភាគី នៅពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់នេះ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវសំណួរមានការការពាក់ព័ន្ធ ដោយលោកមេធាវី អាឡាំង វ៉ែនណឺ ដែលបានលើកឡើងអំពីបញ្ហានូវសេចក្តីសម្រេចនូវសំណូមពររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលសុំបង្ហាញនូវរបាយការណ៍ *អូអាយអូអេស* ។ ខ្ញុំសូមជម្រាបជូនថា អង្គជំនុំជម្រះមិនបានព្រងើយកន្តើយនឹងបញ្ហានេះទេ អង្គជំនុំជម្រះក្រោយពីបានទទួលនូវសំណូមពររបស់មេធាវី បានរៀបចំនូវលិខិតដើម្បីស្នើសុំទៅខាងអគ្គលេខាអង្គការសហប្រជាជាតិ ដើម្បីឆ្លើយតបអំពីបញ្ហាទាំងអស់ដែលមានការពាក់ព័ន្ធទៅនឹងរបាយ-ការណ៍នោះ ហើយខាងអង្គការសហប្រជាជាតិក៏បានឆ្លើយរួចរាល់ហើយ ហើយការឆ្លើយឆ្លងគ្នានោះរហូតដល់ពីរលិខិតឯណោះ ដោយសារតែមានការយឺត គឺអង្គជំនុំជម្រះបានរំឭកមួយទៀត ។

[១១:២២:៤៩]

អ៊ីចឹង ការឆ្លើយរបស់អគ្គលេខាអង្គការសហប្រជាជាតិតបនឹងលិខិតរបស់អង្គជំនុំជម្រះសាលាដំបូង គឺមានលិខិតពីរ ហើយឃើញថាមិនមានបញ្ហាអីទេ ហើយអង្គជំនុំជម្រះបានសម្រេចនៅក្នុងពីរសប្តាហ៍កន្លងមកហើយនេះ នូវការសម្រេចឯកភាពគ្នាក្នុងការរៀបចំនូវសេចក្តីសម្រេច ដើម្បី-- អំពីបញ្ហានេះ ដើម្បីដាក់ជូនភាគី ហើយយើងបានត្រួតពិនិត្យអម្បាញ់មិញនេះ ឃើញថាការរៀបចំបានរួចរាល់ហើយ ប៉ុន្តែនៅត្រូវការប្រជុំគ្នាដើម្បីផ្ទៀងផ្ទាត់មើលទៅលើខ្លឹមសាររវាងភាសាទាំងបីភាសា ខ្មែរ បារាំង អង់គ្លេស មុននឹងចុះហត្ថលេខាចេញ ។ អ៊ីចឹង ប្រហែលជាមិនយូរទេលើបញ្ហានេះ ។ ហើយជម្រាបថា បញ្ហានេះជាបញ្ហាអង្គជំនុំជម្រះបានយល់ច្បាស់ថា ត្រូវតែចេញមុនពេលអង្គជំនុំជម្រះប្រកាស

នូវលទ្ធផលនៃសេចក្ដីសម្រេចនូវសាលក្រមរបស់ខ្លួន បើពុំដូច្នោះទេ គឺតម្លៃយុត្តិធម៌នឹងអាចថយចុះ ឬក៏មិនមានតម្លៃទេ ប្រសិនបើមិនជូនដំណឹងពីបញ្ហាឆ្លើយតបអំពីបញ្ហានេះមុននោះ ។ សូមជ្រាប ។

ហើយអរគុណដល់លោក ហ្វ្រង់ស្វ័រ រូ ដែលបានសួរពីបញ្ហាអម្បាញ់មិញ អំពីពេលវេលាថាតើចំណាយពេលវេលាប៉ុន្មាន ដើម្បីភាគីឡើងធ្វើសេចក្ដីសន្និដ្ឋាន លាយលក្ខណ៍អក្សរបញ្ចប់កិច្ចពិភាក្សាដេញដោលនេះ ។ ហើយឥឡូវនេះ ដើម្បីឲ្យបានច្បាស់លាស់ អង្គជំនុំជម្រះចង់បាននូវជំហរ ឬក៏បំណងរបស់ភាគីវិញ ថាតើភាគីដែលនានាហ្នឹងគឺត្រូវការពេលវេលាប៉ុន្មានដើម្បីធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល?

ជាបឋមនេះ គឺសួរទៅតំណាងសហព្រះរាជអាជ្ញា ថាតើពេលវេលាប៉ុន្មានសមរម្យក្នុងការធ្វើសេចក្ដីថ្លែងការណ៍ផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោល ដែលយើងបានកំណត់កាលបរិច្ឆេទរួចហើយ គឺយើងធ្វើនៅថ្ងៃទី២៣, ២៤, ២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

[១១:២៥:០០]

**លោក អានីស អះមេដ៖**

ដោយសារតែយើងមិនបានយកមកដាក់ក្នុងរបៀបវារៈនៃក្នុងសវនាការយើងថ្ងៃនេះ ខ្ញុំមិនអាចផ្ដល់ចម្លើយជាក់លាក់នោះទេដោយសារតែខ្ញុំត្រូវពិភាក្សាជាមួយនឹងសហព្រះរាជអាជ្ញា ហើយខ្ញុំសូមធ្វើការជម្រាបជូនបញ្ហានេះតាមរយៈក្រឡាបញ្ជី ថាតើលោកចៅក្រមគិតយ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

អរគុណ ។ ចុះខាងមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីវិញ តើមានបានគិតហើយនៅ ថាតើត្រូវការពេលវេលាប៉ុន្មានដើម្បីធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោល ហើយរបៀបធ្វើ តើធ្វើយ៉ាងម៉េច? ធ្វើរួមគ្នា ឬក៏ធ្វើដោយឡែកពីគ្នា? សូមបង្ហាញជំហរឲ្យបានច្បាស់បញ្ហានេះ ដើម្បីឲ្យអង្គជំនុំជម្រះយកទៅពិនិត្យពិចារណា ហើយនិងចេញសេចក្ដីណែនាំជាលាយលក្ខណ៍អក្សរក្នុងការអនុវត្តជាក្រោយ ។

**លោក អាឡាំង វែនណឺ៖**

លោកប្រធាន! ដូចដែលលោកប្រធានយល់ហើយ គឺមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ មិនមានវត្តមាននៅទីនេះទេ ដូច្នេះហើយគឺខ្ញុំត្រូវការពេលវេលាមួយចំនួន មិនយូរទេពិភាក្សាគ្នា ហើយយើងអាចជម្រាបតាមរយៈក្រឡាបញ្ជី ដើម្បីឲ្យយើងពិភាក្សាគ្នាបាន ។ ដូច្នេះហើយ យើងខ្ញុំសុំរយៈពេល

មួយចំនួនដើម្បីពិភាក្សាគ្នា ហើយយើងឆ្លើយតបទៅលើបញ្ហានេះតាមរយៈក្រឡាបញ្ជី ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ចុះមេធាវីការពារក្ដីវិញ តើត្រូវការពេលវេលាប៉ុន្មានដើម្បីធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល? ហើយសូមឲ្យពិចារណាផងដែរ ទាំងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ដោយជនជាប់ចោទ ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន! មេធាវីការពារក្ដី ចំពោះខ្ញុំសុំរយៈពេលបីម៉ោង លោក ហ្វ្រង់ស្វ័រ សុំប្រាំមួយម៉ោង អ៊ីចឹងវាប្រាំបួនម៉ោង ។

**ប្រធានអង្គជំនុំ៖**

ចុះខាងជនជាប់ចោទ លោកបានពិភាក្សាទេ តើពេលវេលាប្រាំបួនម៉ោងដែលលោកសុំនេះ ទាំងរួមទាំងជនជាប់ចោទផង ឬក៏ជនជាប់ចោទត្រូវសុំពេលវេលាដោយឡែក?

[១១:២៧:៣៤]

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន! ជនចាប់ចោទគាត់សុំដោយឡែក ហើយដោយឡែកនេះ គាត់នឹងជម្រាបលោកប្រធាននៅពេលក្រោយដែរ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ សូមអញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំនឹងចែករំលែកពេលវេលារបស់ខ្ញុំជាមួយនឹងមេធាវី កានីហ្សាសេ ដែលជាមេធាវីអន្តរជាតិផងដែរ ។ ដូច្នេះហើយខ្ញុំសុំរយៈពេលប្រាំមួយម៉ោង ហើយនឹងចែករំលែកប្រាំមួយម៉ោងនេះ រវាងខ្ញុំនឹងមេធាវី កានីហ្សាសេ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះឃើញថា កិច្ចដំណើរការពិភាក្សាអំពីការដាក់ឯកសារ នៅចំពោះមុខអង្គជំនុំជម្រះរបស់ភាគីឃើញថាដល់ទីបញ្ចប់ហើយ ។

[១១:២៨:៥៨]

ហើយអង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនិងសាធារណជនថា នៅរសៀលនេះអង្គជំនុំជម្រះនឹងមិនធ្វើសវនាការទេ ។ ហើយម៉្យាងទៀត នៅសប្តាហ៍ក្រោយក៏អង្គជំនុំជម្រះមិនធ្វើសវនាការដែរ ។ ដោយឡែកអង្គជំនុំជម្រះនឹងប្រជុំពិភាក្សាសម្រេច ចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរទៅលើបញ្ហានានាដែលភាគីបានស្នើសុំដាក់ឯកសារ និងមានការតជំទាស់គ្នាតាំងពីម្សិលមិញ ហើយរហូតដល់ព្រឹកនេះ ។ ក្នុងករណីចាប់បាច់បន្ទាប់ពីការចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរហើយ អង្គជំនុំជម្រះនឹងកំណត់កាលបរិច្ឆេទថ្មីដើម្បីធ្វើសវនាការលើសេចក្តីសម្រេច ដែលនឹងចេញនោះ ។

ដោយឡែក បញ្ហាពេលវេលាសម្រាប់ភាគីឡើងធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោល ដែលអង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទរួចហើយ គឺគ្រោងធ្វើនៅថ្ងៃទី២៣, ២៤, ២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ខាងមុខនោះ អង្គជំនុំជម្រះនឹងជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីជាក្រោយបន្ទាប់ពីអង្គជំនុំជម្រះបានទទួលនូវសំណូមពររបស់ភាគីនានាបន្ទាប់ពីពេលនេះទៅ ។ ហើយអង្គជំនុំជម្រះសង្ឃឹមថា ភាគីទាំងអស់នឹងផ្តល់ព័ត៌មានដល់អង្គជំនុំជម្រះតាមរយៈក្រឡាបញ្ជី ប្រហែលជាមិនយូរទេ ដើម្បីអង្គជំនុំជម្រះចេញសេចក្តីសម្រេច ហើយឲ្យភាគីលៃពេលវេលាសមស្របដើម្បីធ្វើសេចក្តីថ្លែងការណ៍បញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន ឬក៏អាចគណនានៅក្នុងអំឡុងពេលនៃដំណើរការសវនាការស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់ហ្នឹង ដោយយើងអាចពន្យារពេលពីរបីថ្ងៃ ឬក៏លើសពីបីថ្ងៃអីអ៊ីចឹង ដើម្បីឲ្យយើងគណនាឲ្យបានត្រឹមត្រូវ ។

ដូច្នេះដំណើរការសវនាការនេះ ថ្ងៃនេះអង្គជំនុំជម្រះប្រកាសផ្អាកសវនាការត្រឹមនេះ ។ ចំណែកឯសវនាការចាំបាច់ប្រសិនបើមាននៅពេលក្រោយ អង្គជំនុំជម្រះនឹងជូនដំណឹងដល់ភាគីនិងសាធារណជននៅពេលក្រោយ ។

អនុរក្សមន្ទីឃុំឃាំងឲ្យនាំជនជាប់ចោទ ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយរង់ចាំការកោះហៅជាថ្មីពីអង្គជំនុំជម្រះប្រសិនបើករណីចាំបាច់ ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង ១១:៣២នាទី]*